**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale De Droit Et des Sciences Economiques**

**Royal University of Law and Economic**


## សារណាបញ្ចប់ការសិក្សា

# សុពលភាពនៃកិច្ចសន្យា

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **សំខឹម មុីនមេត្តា**

កញ្ញា **នៃ ច័ន្ទគ្រឹះហ្វា**

សាស្ត្រាចារ្យណែនាំ

លោក **ទេព សុខ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ សំខឹម ម៉ីនមេត្តា និង ផៃ ច័ន្ទគ្រឹះហ្វា ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្រ្តក្រុម L4A4 ជំនាន់ទី២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៩-២០២០ សូមលំឱនកាយវាចារចិត្តដើម្បីសម្តែងការគោរព ការដឹងគុណ និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះ

លោកឪពុក អ្នកម្តាយ នីមួយៗនៃសមាជិកក្រុម ដែលបានផ្តល់កំណើតភាពកក់ក្តៅ និងផ្គត់ផ្គង់ការសិក្សា ទំនុបបំរុងថវិកា ។ គុណូបការៈរបស់លោកទាំងពីរមានទំហំធំធេង លោកទាំងពីរលះបង់កម្លាំងកាយកម្លាំងចិត្ត ពលីកម្មគ្រប់បែបយ៉ាង ដើម្បីកូន ចិញ្ចឹមបីបាច់ ថែរក្សា ថ្នាក់ថ្នម ផ្តល់សេចក្តីស្រលាញ់ ការអប់រំ ការប្រៀនប្រដៅឲ្យដើរតាមគន្លងធម៌។

សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានផ្តល់កន្លែងសម្រាប់និស្សិតគ្រប់ជំនាន់បានក្រេបយកចំណេះដឹង និងបទពិសោធន៍ មកអភិវឌ្ឍខ្លួន និងបំពេញការងារប្រកបដោយសុចរិតភាព និងតម្លាភាពចំពោះមុខច្បាប់ និងសង្គមជាតិទាំងមូល។

ជាពិសេសជូនចំពោះលោកសាស្រ្តាចារ្យ **ធេព សុខ** ដែលជាសាស្រ្តាចារ្យបង្ហាត់បង្រៀនយើងខ្ញុំផ្ទាល់ និងដោយបានចំណាយពេលវេលាដ៏មានតម្លៃ ព្រមទាំងលះបង់កម្លាំងកាយចិត្ត មិនខ្លាចនឿយហត់ធ្វើការបង្ហាត់បង្រៀន នឹងផ្តល់អនុសាសន៍ល្អៗ ដើម្បីជួយឲ្យការសិក្សានិស្សិតទាំងអស់ទទួលបាននូវភាពជោគជ័យ។

ជាចុងបញ្ចប់យើងខ្ញុំ សូមថ្លែងអំណរអរគុណ និងសូមប្រសិទ្ធិពរជ័យដល់វត្ថុសក្តិសិទ្ធិ សិរីមង្គលវិបុលសុខគ្រប់ប្រការក្នុងលោក សូមជួយថែរក្សាអ្នកមានគុណទាំងឡាយដូចបានរៀបរាប់ខាងលើ អោយជួបតែពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានចំណាយពេលវេលាដ៏មានតម្លៃបួនឆ្នាំក្រោមការបណ្ដុះបណ្ដាល បង្ហាត់បង្រៀនពីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងដើម្បីឆ្លើយតបនឹងការខិតខំប្រឹងប្រែង ការលះបង់របស់សាស្ត្រាចារ្យ ក៏ដូចជាតម្រូវការចាំបាច់របស់សាកលវិទ្យាល័យ យើងខ្ញុំទទួលបានប្រធានបទ "**សុពលភាពនៃកិច្ចសន្យា**" ធ្វើជាសារណាសម្រាប់ឆ្នាំបញ្ចប់នេះ។

ការលើកយកប្រធានបទស្រាវជ្រាវនេះមកបកស្រាយ ក្នុងគោលបំណងពង្រីកចំណេះដឹងផ្នែកនេះឲ្យកាន់តែស៊ីជម្រៅ ពីព្រោះបញ្ហាបច្ចុប្បន្នភាព នៅក្នុងជីវភាពប្រចាំថ្ងៃជាក់ស្ដែងគឺមានបញ្ហា វិវាទឈ្លោះប្រកែកគ្នា ក្នុងកិច្ចសន្យារវាងគូភាគីពីរ ឬច្រើននាក់ ដោយមិនយល់ច្បាស់អត្ថន័យក្នុងកិច្ចសន្យា។ យើងខ្ញុំមានសេចក្ដីសោមនស្សរីករាយជាខ្លាំង ដែលបានធ្វើកិច្ចការស្រាវជ្រាវនេះឡើង យើងខ្ញុំសង្ឃឹមថា នឹងចូលរួមចំណែកក្នុងការជួយដល់និស្សិត ក្នុងការពង្រីកចំណេះដឹង និងផ្ដល់គំនិតបន្ថែមទៀត។

ជាទីបញ្ចប់ យើងខ្ញុំសង្ឃឹមថា សិស្សានុសិស្ស ចូលរួមវាយតម្លៃ និងបញ្ចេញមតិរិះគន់ក្នុងន័យស្ថាបនាដើម្បីបំពេញចន្លោះខ្វះខាត លើកំហុសដោយអចេតនា ទាំងអក្ខរាវិរុទ្ធ ទាំងការប្រើពាក្យពេចន៍ខ្លឹមសារ ឬអត្ថន័យនៅក្នុងប្រធានបទស្រាវជ្រាវនេះ និងគោរពជូនពរដល់អ្នកសិក្សាទាំងអស់ ជួបនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ................................................................ ១

## ជំពូក១

## ការបង្ហាញឆន្ទៈ និងកិច្ចសន្យា

**១.១ ការបង្កើតកិច្ចសន្យាដោយសំណើ និងស្វីការ** ........................ ៣

១.១.១ គោលការណ៍ ........................................................ ៣

១.១.២ ករណីលើកលែង ................................................... ៣

**១.២ និយមន័យនៃសំណើ និងស្វីការ** ........................................ ៣

១.២.១ និយមន័យនៃសំណើ ............................................... ៣

១.២.២ ភាពខុសគ្នារវាងសំណើ និងការអញ្ជើញឲ្យធ្វើសំណើ ................... ៣

១.២.៣ ពេលបង្កើតអានុភាពនៃសំណើ ....................................... ៤

១.២.៤ ពេលដែលបង្កើតអានុភាពនៃស្វីការ .................................. ៥

**១.៣ សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្វីការ និង ការដកសំណើនោះ** ....... ៥

**១.៤ សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ និងការដកសំណើនោះ** ........ ៦

១.៤.១ ករណីគូភាគីដែលកំពុងនិយាយគ្នា ..................................... ៦

១.៤.២ ករណីគូភាគីដែលមិននិយាយគ្នា ...................................... ៦

១.៤.៣ ពេលដែលបង្កើតអានុភាពនៃការដកសំណើ ............................. ៦

**១.៥ ពេលការបង្កើតកិច្ចសន្យាគោលការណ៍នៃការមកដល់នៃស្វីការ** ................ ៦

**១.៦ ការមកដល់យឺតយ៉ាវនៃស្វីការ** ............................................ ៧

**១.៨ ការបង្កើតកិច្ចសន្យាដោយសកម្មភាពដែលត្រូវបានចាត់ទុកថាជាស្វីការ** ....... ៨

**១.៩ ការដកសំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់** ....................... ៨

## ជំពូក២

## សុពលភាព និងមោឃភាពនៃកិច្ចសន្យា

**២.១ មូលដ្ឋានគតិយុត្តនៃសកម្មភាព** ........................................ ៩

២.១.១ ការបង្ហាញឆន្ទៈ ..................................................... ៩

២.១.២ កិច្ចសន្យា ..... ៩
២.១.៣ និយមន័យសកម្មភាព ..... ១០
**២.២ បញ្ញត្តិស្ដីពីមោឃភាពនៃកិច្ចសន្យា** ..... ១០
២.២.១ ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ..... ១០
២.២.២ ផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ..... ១១
២.២.៣ ផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារដោយច្បាប់ ..... ១១
២.២.៤ ការបង្ហាញឆន្ទៈមិនពិត ..... ១២

**ជំពូក៣**

**សុពលភាព និងការលុបចោលនៃកិច្ចសន្យា**

**៣.១ សកម្មភាពដែលអាចលុបចោលបាន** ..... ១៤
**៣.២ អ្នកមានសិទ្ធិលុបចោល** ..... ១៤
**៣.៣ បញ្ញត្តិស្ដីពីការលុបចោលនៃកិច្ចសន្យា** ..... ១៥
៣.៣.១ ការភាន់ច្រឡំ ..... ១៥
៣.៣.២ ការឆបោក ..... ២២
៣.៣.៣ ពត៌មានមិនពិត ..... ២៧
៣.៣.៤ ការរំលោភបំពានលើស្ថានភាព ..... ២៨
៣.៣.៥ ការគំរាមកំហែង ..... ២៩
៣.៣.៦ ការកេងយកចំណេញហួសហេតុ ..... ៣០
៣.៣.៧ ឋបនីយផ្លូវចិត្ត ..... ៣០
៣.៣.៨ អលទ្ធភាពតាំងពីដំបូង ..... ៣២
**៣.៤ វិធីនៃការលុបចោល ឬ សច្ចានុមតិ** ..... ៣៦
៣.៤.១ អ្នកមានសិទ្ធិផ្ដល់សច្ចានុមតិ និងលក្ខខណ្ឌនៃការផ្ដល់សច្ចានុមតិ ..... ៣៦
៣.៤.២ សច្ចានុមតិដែលច្បាប់បានកំណត់ ..... ៣៧
៣.៤.៣ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល ..... ៣៨
**សេចក្ដីសន្និដ្ឋាន** ..... ៣៩
**អនុសាសន៍** ..... ៤១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលបានស្ថិតនៅក្នុងសង្គ្រាមរ៉ាំរ៉ៃអស់រយៈកាលជាច្រើនឆ្នាំមកហើយ ជាពិសេសគឺនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលវិស័យផ្សេងៗនៅក្នុងប្រទេសត្រូវបានធ្លាក់ចុះស្ទើរទាំងស្រុង។ ក្រោយពីសង្គ្រាមរ៉ាំរ៉ៃនៅក្នុងប្រទេសបានបញ្ចប់ទៅវិស័យនានានៅក្នុងព្រះរាជាណាចក្រកម្ពុជាក៏បានចាប់ ផ្តើមមានការអភិវឌ្ឍន៍បន្តិចម្តងៗ ក្នុងនោះ វិស័យសេដ្ឋកិច្ចក៏មានការរីកចម្រើនផងដែរ។ បច្ចុប្បន្ននេះមានការរីកចម្រើន តាមរយៈការប្រែប្រួលផ្នែកសេដ្ឋកិច្ចក៏ដូចជាការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្នុងសង្គម។

នៅក្នុងជីវភាពប្រចាំថ្ងៃ យើងសង្កេតឃើញថា ប្រជាពលរដ្ឋនៅក្នុងសង្គមខ្មែរបានបង្កើតទំនាក់ទំនងគតិយុត្តតាមរយៈកិច្ចសន្យាស្ទើរតែជាប្រចាំថ្ងៃ និងគ្រប់ទីកន្លែង មិនថាទីប្រជុំជន ទីដាច់ស្រយាលឡើយ។ ជាក់ស្តែងសង្គមខ្មែរបច្ចុប្បន្ន ដែលឲ្យនិយមន័យកិច្ចសន្យា គឺជាការព្រមព្រៀងគ្នារវាងពីរភាគី ឬច្រើនភាគី ដែលកើតចេញពីឆន្ទៈ ដើម្បីបង្កើត ឬរំលត់កាតព្វកិច្ចអ្វីមួយ ។ តាមធម្មតា កិច្ចសន្យាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។ដើម្បីធានាដល់ការធ្វើជំនួញ ជាពិសេសទំនាក់ទំនងក្នុងវិស័យពាណិជ្ជកម្មរវាងបុគ្គលឯកជននោះ ការបង្កើតនូវលិខិតយថាភូតពីការព្រមព្រៀងគ្នារវាងភាគីទាំងសងខាង គឺជាការចាំបាច់។ ចំពោះកិច្ចសន្យាដែលចាត់ទុកថាត្រឹមត្រូវតាមគតិច្បាប់ លុះត្រាតែភាគីទាំងសងខាងគោរពនូវលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់នៅក្នុងដំណាក់កាលបង្កើតកិច្ចសន្យា នោះ។

កិច្ចសន្យាត្រូវចាត់ទុកថាមានសុពលភាព អាចយកទៅអនុវត្តបានលុះត្រាតែកិច្ចសន្យានោះត្រូវបានបង្កើតឡើងដោយមានការព្រមព្រៀង គ្នារវាងគូភាគីនៃកិច្ចសន្យានោះ។ ហើយដែលជាទូទៅកិច្ចសន្យានោះត្រូវមានកម្មវត្ថុស្របច្បាប់ និងត្រូវធ្វើឡើងដោយភាគីមានសមត្ថភាពក្នុងការចុះកិច្ចសន្យា។ នៅក្នុងករណីខ្លះ ទោះបីកិច្ចសន្យានោះត្រូវធ្វើ ដោយស្របទៅនឹងគោលគំនិតខាងលើក៏ដោយក៏វាអាចត្រូវបានលុបចោលបានផងដែរ ប្រសិនបើការបង្កើតកិច្ចសន្យានោះមានវិការៈ (វិការៈនៃការព្រមព្រាង) រួចមានដូចជា កិច្ចសន្យានោះកើតឡើងដោយមានការភ័ន្តច្រឡំ (មាត្រា៣៥៦) ការឆបោក (មាត្រា ៣៤៧) ការរំលោភបំពានលើស្ថានភាព (មាត្រា ៣៤៩) ការគម្រាមកំហែង (មាត្រា៣៥០) និងអំពើកេងយកចំណេញហួសហេតុ (មាត្រា ៣៥១) ជា ដើម។

លើសពីនេះទៅទៀតកិច្ចសន្យា មានអានុភាពនៅពេលដែលមានសំណើរ និងស្វីការត្រូវគ្នា ។ ក៏ប៉ុន្តែនៅក្នុងករណីដែលបង្ហាញឆន្ទៈមានវិការៈ ឬខ្លឹមសារនៃសកម្មភាពផ្ទុយនឹងច្បាប់ ឬភាពត្រឹមត្រូវនៅក្នុងសង្គម នោះអានុភាពនឹងត្រូវបានបដិសេធដោយក្រមរដ្ឋប្បវេណី ។ ដូច្នេះ ដើម្បីឲ្យកិច្ចសន្យាមួយមានសុពលភាព កិច្ចសន្យានោះត្រូវបំពេញឲ្យបាននូវលក្ខខណ្ឌចាំបាច់គឺ សំណើរ និងស្វីការត្រូវគ្នា និងលក្ខខណ្ឌគ្រប់គ្រាន់គឺមាន លក្ខខណ្ឌទូទៅទាក់ទងនឹងភាគីដែលរួមមានសមត្ថភាពទទួលសិទ្ធិ សមត្ថភាពខាងឆន្ទៈ សមត្ថភាពក្នុងការធ្វើសកម្មភាព និងគ្មានវិការៈក្នុងការបង្ហាញឆន្ទៈ និង លក្ខខណ្ឌទូទៅទាក់ទងនឹងខ្លឹមសារនៃកិច្ចសន្យាដែលរួមមាន ភាពច្បាស់លាស់ ភាពស្របច្បាប់ ភាពសមស្របតាមស្ថានភាពសង្គម និងភាពគ្មានការបង្ហាញឆន្ទៈមិនពិត។

ប្រសិនបើយើងពិនិត្យមើលឲ្យច្បាស់ កិច្ចសន្យាមានសុពលភាព នៅពេលការបង្ហាញឆន្ទៈរបស់ភាគីទាំងពីរស្របគ្នាទៅវិញទៅមក។ ប្រសិនបើគ្មានការបង្ហាញឆន្ទៈដែលមានអានុភាពដែលជាធាតុផ្សំនៃកិច្ចសន្យាទេ នោះកិច្ចសន្យាមានចំណងចងភាគីទាំងពីរដែរឬទេ ?

ដោយមើលឃើញអំពីបញ្ហាដែលបានលើកឡើងខាងលើនេះ ទើបជំរុញឲ្យពួកខ្ញុំទាំងពីរនាក់ មានបំណងធ្វើការស្រាវជ្រាវប្រធានបទអំពី **សុពលភាពនៃកិច្ចសន្យា** ។

ដើម្បីអាចឆ្លើយតបបាន នឹងសំណួរខាងលើ យើងសូមធ្វើការសិក្សាជាដំបូងនូវបណ្ដា ល័ក្ខខ័ណ្ឌ ក៏ដូចជានិយមន័យ ព្រមទាំងការបង្កើតកិច្ចសន្យា បូករួមទាំងការបង្កើតអានុភាពនៃសំណើ ដើម្បីឲ្យកាន់តែច្បាស់ផងដែរ ក្នុងកិច្ចការស្រាវជ្រាវនេះ យើងខ្ញុំបានបែងចែកជា៣ជំពូក ដោយៈ

**ជំពូកទី១ៈ ការបង្ហាញឆន្ទៈនិងកិច្ចសន្យា**

១.១ ការបង្កើតកិច្ចសន្យាដោយសំណើ និងស្វីការ

១.២ និយមន័យនៃសំណើ និងស្វីការ

១.៣ សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្វីការ និងការដកសំណើនោះ

១.៤ សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ និងការដកសំណើនោះ

១.៥ ពេលការបង្កើតកិច្ចសន្យា គោលការណ៍នៃការមកដល់នៃស្វីការ

១.៦ ការមកដល់យឺតយ៉ាវនៃស្វីការ

១.៧ ស្វីការដោយមានបន្ថែមការកែប្រែ

១.៨ ការបង្កើតកិច្ចសន្យាដោយសកម្មភាពដែលត្រូវបានចាត់ទុកថាជាស្វីការ

១.៩ ការដកសំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់

**ជំពូក ២ សុពលភាព និងមោឃភាពនៃកិច្ចសន្យា**

២.១ មូលដ្ឋានគតិយុត្តនៃសកម្មភាព

២.២ បញ្ញត្តិស្តីពី មោឃភាពនៃកិច្ចសន្យា

**ជំពូក ៣ មោឃៈភាព និងការលុបចោល**

៣.១ សកម្មភាពដែលអាចលុបចោលបាន

៣.២ អ្នកមានសិទ្ធិលុបចោល

៣.៣ បញ្ញត្តិស្តីពីការលុបចោលនៃកិច្ចសន្យា

៣.៤ វិធីនៃការលុបចោល ឬសច្ចានុមតិ

# ជំពូក ១

# ការបង្ហាញឆន្ទៈ និងកិច្ចសន្យា

## ១.១ ការបង្កើតកិច្ចសន្យាដោយសំណើ និងស្វីការ

### ១.១.១ គោលការណ៍

ជាគោលការណ៍ ការបង្កើតកិច្ចសន្យាគឺជាការបង្កើតការព្រមព្រៀងគ្នាទៅវិញទៅមករវាងគូភាគីពីរ ឬច្រើននាក់ ។ យោងទៅតាម Black's Law Dictionary ពាក្យកិច្ចសន្យាមានន័យថា "ការព្រមព្រៀងរវាងភាគីពីរ ឬច្រើននាក់ក្នុងការបង្កើតកាតព្វកិច្ចដែលអាចអនុវត្តបាន ឬក៏ទទួលស្គាល់ដោយច្បាប់ "។ គោលការណ៍នៃការបង្កើតកិច្ចសន្យាគឺជាគោលការណ៍សេរីភាពរបស់បុគ្គលក្នុងការព្រមព្រៀងធ្វើអ្វីមួយ។ ទោះជាយ៉ាងក៏ដោយ គេសន្មតថា កិច្ចសន្យាមួយមានអានុភាពលុះត្រាតែសំណើ និងស្វីការត្រូវគ្នា។[1]

### ១.១.២ ករណីលើកលែង

ចំពោះកិច្ចសន្យាដែលទាក់ទងនឹងការធ្វើអនុប្បទាន ឬធ្វើលទ្ធកម្មនៃអចលនវត្ថុ វាអាចមានអានុភាពទៅបានលុះត្រាតែបានធ្វើលិខិតយថាភូត។ លិខិតយថាភូតត្រូវបានចែងយ៉ាងច្បាស់នៅ ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១។

## ១.២. និយមន័យនៃសំណើ និងស្វីការ

### ១.២.១ និយមន័យនៃសំណើ

ការស្វែងយល់ពីអត្ថន័យនៃសំណើ និង ស្វីការគឺជាការចាំបាច់ក្នុងការសិក្សាពីកិច្ចសន្យា ។ សំណើគឺជា "ការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ"។[2]

### ១.២.២ ភាពខុសគ្នារវាងសំណើ និងការអញ្ជើញឲ្យធ្វើសំណើ

ទោះបីជាមានចែងច្បាស់ពីនិយមន័យនៃសំណើក៏ដោយ គេពិនិត្យឃើញមានភាពខុសគ្នារវាងសំណើ និងការអញ្ជើញឲ្យធ្វើសំណើ។ សំណើ គឺជាការបង្ហាញឆន្ទៈថានឹងភ្ជាប់ជាមួយចំណងនៃកិច្ចសន្យា ក្នុងករណីដែលភាគីម្ខាងផ្តល់ស្វីការឲ្យស្របគ្នាទៅនឹងសំណើនោះ។ ចំណែកឯការអញ្ជើញឲ្យសំណើ គឺជាអញ្ជើញឲ្យភាគីផ្សេងឲ្យធ្វើសំណើមកកាន់ខ្លួន ។

**ឧទាហរណ៍ខាងក្រោមបង្ហាញអំពីការអញ្ជើញឲ្យសំណើ**

ហាង A បានបិតប្រកាសជ្រើសរើសបុគ្គលិកចំនួន ១នាក់ នៅខាងមុខហាងរបស់ខ្លួន ដោយដាក់ល័ក្ខខណ្ឌជ្រើសរើស។ ការប្រកាសផ្សាយនេះជាការអញ្ជើញឲ្យធ្វើសំណើលើកិច្ចសន្យាការងារ រីឯបុគ្គលដែលមាន

[1] មាត្រា ៣៣៦ កថាខណ្ឌទី ១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[2] មាត្រា ៣៣៧ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ចំណាប់អារម្មណ៍លើការប្រកាសនោះ ហើយបានដាក់ពាក្យសុំធ្វើការ គឺជាការដាក់សំណើ ។ ក្រោយពីហាង A បានពិនិត្យលើពាក្យសុំ ហើយបានសម្រេចយកបុគ្គលណាម្នាក់ជាបុគ្គលិក គឺជាស្ទីការទៅលើសំណើ ពេលនោះកិច្ចសន្យាការងារត្រូវបានកើតឡើង។

លោក សំណាង ជាអ្នកលក់សម្លៀកបំពាក់នៅក្នុងហាងមួយដោយដាក់តម្លៃនៅលើសម្លៀកបំពាក់នីមួយៗ លោកមិនបានសំណើទេគ្រាន់តែអញ្ជើញឲ្យភ្ញៀវធ្វើសំណើ ។ នៅពេលលោក សម្បត្តិ និយាយទៅកាន់លោក សំណាង ថាគាត់នឹងទិញសម្លៀកបំពាក់មួយកំផ្លេនេះ នោះសំណើនឹងកើតឡើងភ្លាម ហើយនៅពេលលោក សំណាង យល់ព្រមលក់សម្លៀកបំពាក់នោះ ពោលគឺផ្តល់ស្ទីការត្រូវគ្នាទៅនឹងសំណើដែលបានលើកឡើង នោះកិច្ចសន្យាក៏ត្រូវបានបង្កើតឡើងដែរ។

ក្រុមហ៊ុនធានារ៉ាប់រង A បានប្រកាសផ្សព្វផ្សាយលក់ធានារ៉ាប់រងសុខភាព។ នេះជាការអញ្ជើញឲ្យធ្វើសំណើ។ B ជាអតិថិជនទិញធានារ៉ាប់រងសុខភាពទៅតាមល័ក្ខខ័ណ្ឌក្រុមហ៊ុនកំណត់ ។ ករណីនេះ B ជាអ្នកដាក់សំណើ ។ នៅពេលក្រុមហ៊ុន A យល់ព្រមលក់ធានារ៉ាប់រងឲ្យ B ពោលគឺផ្តល់ស្ទីការត្រូវគ្នាទៅនឹងសំណើរបស់ B នោះកិច្ចសន្យាក៏ត្រូវបានបង្កើតឡើង ។

**១.២.៣ ពេលបង្កើតអានុភាពនៃសំណើ**

សំណើមានអានុភាពទៅបាន លុះត្រាតែសំណើនោះបានទៅដល់ភាគីម្ខាងទៀត។[3] ឧបមា B ជាអ្នកលក់កង់ ហើយលោកA និយាយប្រាប់ B ថានឹងទិញកង់ណាមួយពី B ។ ដូច្នេះសំណើដែល A ផ្តល់ទៅឲ្យB មានអានុភាព ។

ប៉ុន្តែប្រសិនបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើដល់ ឬមុនពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតឡើងឡើយ។[4] ឧទាហរណ៍ A បានស្នើ C ឲ្យជូនដំណឹងទៅ B ថាខ្លួនទិញកង់មួយពី B (សំណើ)។ តែក្រោយមក A បានស្នើ D ឲ្យជូនដំណឹងទៅ B ថាខ្លួនមិនទិញកង់នោះទេ (ការដកសំណា) ។ ករណីនេះប្រសិនបើ D បានប្រាប់ B ពីការណ៍ដែល A ឈប់ទិញកង់នៅចំពេល ឬ មុនពេលដែល C ប្រាប់ B ពីការទិញកង់របស់ A នោះសំណើរបស់ A តាមរយៈ C មិនមានអានុភាពឡើយ ។

**និយមន័យស្ទីការ**

ស្ទីការគឺជា "ការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ"។[5] ឧទាហរណ៍ បើ A ប្រាប់ B ហើយ B យល់ព្រមលក់កង់នោះ មានន័យថា ការឆ្លើយតបរបស់ B គឺជាស្ទីការ ។

**សំណើខ្វែង**

[3] មាត្រា ៣៣៧ កថាខណ្ឌទី២ វាក្យខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[4] មាត្រា៣៣៧ កថាខណ្ឌទី២ វាក្យខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[5] មាត្រា៣៣៧ កថាខណ្ឌទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

សំណើខ្វែងគឺជា "សំណើមួយដែលធ្វើឡើងដោយអ្នកណាម្នាក់ ដោយមិនបានដឹងថាអ្នកទទួលសំណើក៏បានដាក់សំណើដូចគ្នាមកកាន់អ្នកស្នើ ។" ឧទាហរណ៍ បើ A ជូនដំណឹងទៅ B ថាទិញកង់ មួយ ។ B ក៏ជូនដំណឹងទៅ A ថានឹងលក់កង់មួយឲ្យ A ដោយមិនបានដឹងពីការជូនដំណឹងរបស់ A ទេ (សំណើខ្វែង) ។ ជាគោលការណ៍ ទោះអ្នកទាំងពីរបានបង្ហាញឆន្ទៈក៏ដោយក៏កិច្ចសន្យាមិនទាន់កើតមានឡើយ ពីព្រោះពួកគេ គ្រាន់តែដាក់សំណើឲ្យគ្នាទៅវិញទៅមកប៉ុណ្ណោះ ។ ប៉ុន្តែប្រសិនបើមានស្ទីការពីភាគីណាមួយម្តងទៀត នោះកិច្ចសន្យានឹងកើតឡើង ។ ម្យ៉ាងទៀត មានទស្សនៈថាដោយសារឆន្ទៈរបស់ភាគីទាំងពីរត្រូវគ្នា ហេតុនេះគួរទទួលស្គាល់ថា កិច្ចសន្យានឹងកើតមានបន្ទាប់ពីសំណើក្រោយបានទៅដល់ភាគីម្ខាងទៀត។

### ១.២.៤ ពេលដែលបង្កើតអានុភាពនៃស្ទីការ

មិនខុសពីអានុភាពនៃសំណើទេ អានុភាពនៃស្ទីការកើតមានឡើង លុះត្រាតែស្ទីការនោះបានទៅដល់អ្នកស្នើ ។ ទោះជាយ៉ាងណាក៏ដោយ បើដំណឹងពីការដកស្ទីការបានទៅដល់ក្នុងអំឡុងពេល ឬមុនពេលស្ទីការទៅដល់អ្នកស្នើ នាំឲ្យស្ទីការនោះមិនមានអានុភាពទេ ។ ឧទាហរណ៍ នៅម៉ោង ២:០០រសៀល A បាននិយាយប្រាប់ C ថានឹងទិញកង់ណាមួយជាក់លាក់ដែល B បានដាក់លក់ ។ តែនៅម៉ោង ៣:០០រសៀល បានសម្រេចចិត្តឈប់ទិញកង់នោះវិញ ហើយបានប្រាប់ E ឲ្យជម្រាបជូន B ផង ។ C នឹង E បានជម្រាបជូន B ពីជូនដំណឹងនេះក្នុងពេលជាមួយគ្នា ឬ E បានប្រាប់ B មុនពេលដែល C ជម្រាប B។ ករណីនេះស្ទីការរបស់ A មិនមានអានុភាពទេ ដូច្នេះកិច្ចសន្យាទិញលក់កង់ក៏មិនកើតមានដែរ ។

## ១.៣ សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្ទីការ និង ការដកសំណើនោះ

គេអាចដាក់សំណើ ដោយកំណត់អំឡុងពេលសម្រាប់ស្ទីការ ។ ឧទាហរណ៍ A ប្រកាសលក់ឡានម៉ាកកាមរី ២០០៣ តម្លៃ១៣០០០ដុល្លារ ចាប់ពីថ្ងៃជូនដំណឹងរហូតដល់ថ្ងៃទី៣១ ខែឧសភា ។ ដូច្នេះ សំណើនេះមិនមានអានុភាពទេ ចាប់ពីថ្ងៃទី១ ខែមិថុនា ។ បញ្ហាមានការលំបាកបន្តិច ប្រសិនបើការដាក់សំណើមិនមានបញ្ជាក់ពីអំឡុងពេលច្បាស់លាស់។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ បើមិនបានកំណត់ច្បាស់ពីអំឡុងពេលសម្រាប់ស្ទីការទេ គេអាចនិយាយបានថាអំឡុងពេលនោះចាប់ពីជូនដំណឹង។

ក្នុងករណីដែលសំណើបានកំណត់អំឡុងពេលសម្រាប់ស្ទីការ សំណើនេះមិនអាចដកវិញបានទេ ពីព្រោះគោលបំណងរបស់វា គឺដើម្បីបញ្ជាក់ពីឆន្ទៈរបស់អ្នកស្នើក្នុងការរង់ចាំស្ទីការ ។ ក្នុងករណីអំឡុងពេលសម្រាប់ធ្វើស្ទីការបានផុតកំណត់ សំណើដែលបានកំណត់អំឡុងពេលត្រូវបាត់បង់អានុភាព ដោយស្វ័យប្រវត្តិ ។ ជាមួយគ្នានេះដែរ បើអ្នកស្នើបានដឹងពីការបដិសេធសំណើនៅក្នុងអំឡុងពេលសម្រាប់ស្ទីការ សំណើនោះក៏អស់អានុភាពដែរ។[6]

[6] មាត្រា ៣៣៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## ១.៤ សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ និងការដកសំណើនោះ

### ១.៤.១ ករណីគូភាគីដែលកំពុងនិយាយគ្នា

ក្នុងករណីដែលសំណើគ្មានកំណត់អំឡុងពេលរវាងភាគីដែលកំពុងនិយាយគ្នា ហើយភាគីណាមួយអាចឆ្លើយតបទៅនឹងសំណើភ្លាមៗ ប្រសិនបើភាគីដែលទទួលសំណើមិនបានយល់ព្រមភ្លាមៗទេ សំណើនោះនឹងអស់អានុភាព។[7] ឧទាហរណ៍ A កំពុងនិយាយទៅកាន់ B ថា "ខ្ញុំលក់ឡាននេះឲ្យអ្នកនូវតម្លៃ ១០០០០ដុល្លារ" ហើយ B មិនយល់ព្រមទិញទេ ដូច្នេះ សំណើលក់ឡាន១០០០០ដុល្លារ អស់អានុភាព ។

### ១.៤.២ ករណីគូភាគីដែលមិននិយាយគ្នា

ក្នុងករណីដែលសំណើគ្មានកំណត់អំឡុងពេលរវាងភាគីដែលមិននិយាយគ្នា ដូចជាតាមរយៈការសរសេរសំបុត្រ ការផ្ញើសារតាមរយៈ Email ជាដើម អ្នកស្នើមិនអាចដកសំណើនោះវិញក្នុងអំឡុងពេលសមរម្យបានឡើយ ។ មានភាពមិនច្បាស់លាស់ចំពោះពាក្យថា អំឡុងពេលសមរម្យ ព្រោះវាអាស្រ័យទៅតាមករណីជាក់ស្តែងនៃប្រភេទកិច្ចសន្យា ។ ទោះជាយ៉ាងណាក៏ដោយ ករណីនេះមិនលើកឡើងពីការអស់អានុភាពនៃសំណើទេ ពីព្រោះតែភាពមិនច្បាស់លាស់នៃពេលវេលាដែលអស់អានុភាព ។

### ១.៤.៣ ពេលដែលបង្កើតអានុភាពនៃការដកសំណើ

នៅពេលសំណើត្រូវបានបង្កើត ការដកសំណើនេះមានអានុភាព លុះត្រាតែការជូនដំណឹងរបស់វាបានទៅដល់ភាគីម្ខាងទៀត មុនពេលភាគីម្ខាងទៀតជូនដំណឹងអំពីស្ទីការ ។ ឧទាហរណ៍ A បានប្រាប់ B ថាខ្លួននឹងលក់ផ្ទះមួយល្វែងទៅឲ្យ B ក្នុងតម្លៃ ៥០០០០ ដុល្លារ ។ B មិនទាន់បានឆ្លើយថាយល់ព្រមទិញផង ស្រាប់តែបានដឹងថា A ឈប់លក់ផ្ទះនោះវិញ ។ ករណីនេះ កិច្ចសន្យាមិនកើតឡើងទេ ព្រោះថាការដកសំណើគឺមានអានុភាព។

**ករណីសិក្សា**

X បានធ្វើសំណើបង្កើតកិច្ចសន្យាចំពោះ Y ។ ១០ឆ្នាំក្រោយ Y បានជូនដំណឹងអំពីស្ទីការទៅ X។ តើកិច្ចសន្យាត្រូវបានបង្កើតឡើងដែរ ឬ ទេ ?

ដោយសារសំណើបង្កើតកិច្ចសន្យារបស់ X ចំពោះ Y មិនកំណត់អំឡុងពេលសម្រាប់ស្ទីការដូច្នេះការដែល ១០ឆ្នាំក្រោយមក Y បានជូនដំណឹងពីស្ទីការនាំឲ្យមានកិច្ចសន្យាកើតឡើង ។

## ១.៥. ពេលការបង្កើតកិច្ចសន្យា គោលការណ៍នៃការមកដល់នៃស្ទីការ

កិច្ចសន្យាមួយឡើង នៅពេលដែលអ្នកស្នើបានទទួលដំណឹងអំពីស្ទីការ។[8] ឧទាហរណ៍ A ចង់ទិញឡានម៉ាកក្លូវ៉ាឡាពី B នូវតម្លៃ១៣០០០ដុល្លារ ហើយ B តបទៅវិញថាខ្លួនយល់ព្រមលក់ ។

**ករណីសិក្សា**

---

[7] មាត្រា ៣៣៩ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[8] មាត្រា ៣៤០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

X បានធ្វើសំណើបង្កើតកិច្ចសន្យាចំពោះ Y ។ តើអាចទទួលស្គាល់អំពីការបង្កើតកិច្ចសន្យាបានដែរ ឬទេ ក្នុងករណីខាងក្រោម?

១. Y បានយកលិខិតស្វីការនៃការបង្កើតកិច្ចសន្យាទៅដល់ផ្ទះរបស់ X តែ X មិននៅផ្ទះ ហេតុនេះ Y បានទុកលិខិតនោះនៅផ្ទះរបស់ X រួចត្រឡប់មកវិញ ។

២. Y បានយកលិខិតស្វីការនៃការបង្កើតកិច្ចសន្យាទៅដល់ផ្ទះរបស់ X តែ X មិននៅផ្ទះ ហេតុនេះ Y បានប្រគល់លិខិតនោះដល់ដៃប្រពន្ធរបស់ X ។

៣. Y បានជូនដំណឹងអំពីស្វីការតាមរយៈការផ្ញើសារអេឡិចត្រូនិច ប៉ុន្តែកុំព្យូទ័ររបស់ X ខូច ហេតុនេះ X មិនអាចមើលឃើញសារនោះទេ ។

**ការពិភាក្សា៖**

១.បើ X មកដល់ផ្ទះ ហើយឃើញលិខិតស្វីការនោះ កិច្ចសន្យារវាង X និង Y កើតមាន ។

២.បើប្រពន្ធ X ប្រាប់ពីការប្រគល់លិខិតស្វីការរបស់ Y ទៅដល់ X នាំឲ្យកិច្ចសន្យារវាង X និងYកើតមាន ។

៣.នៅក្នុងអំឡុងពេលកុំព្យូទ័រខូច កិច្ចសន្យាមិនទាន់កើតមានទេ។ ប៉ុន្តែបើកុំព្យូទ័រត្រូវបានជួសជុលរួច ពេល X បើកសារអេឡិចត្រូនិចរបស់ខ្លួន ហើយឃើញស្វីការរបស់ Y កិច្ចសន្យានោះកើតមាន។

## ១.៦. ការមកដល់យឺតយ៉ាវនៃស្វីការ

ក្នុងករណីដែលស្វីការមកដល់អ្នកស្នើយឺតជាងអំឡុងពេលដែលកំណត់ ហើយអ្នកស្នើដឹងអំពីស្ថានភាពដែលស្វីការនឹងមកដល់ជាធម្មតាក្នុងអំឡុងពេលកំណត់ តែបែរជាមិនឃើញមកដល់ ហើយក៏បានជូនដំណឹងអំពីការយឺតយ៉ាវ នោះស្វីការមិនមានអានុភាពទេ។[9] ប៉ុន្តែ បើអ្នកស្នើមិនបានជូនដំណឹងអំពីការយឺតយ៉ាវ ដោយសារការធ្វេសប្រហែសរបស់ខ្លួននោះស្វីការនឹងមានសុពលភាព។ ទោះជាយ៉ាងណាក៏ដោយ ស្វីការដែលអស់សុពលភាពនោះ អាចត្រូវបានចាត់ទុកជាសំណើថ្មីបាន ។

## ១.៧. ស្វីការដោយមានបន្ថែមការកែប្រែ

នៅពេលទទួលបានសំណើ អ្នកធ្វើស្វីការដាក់ល័ក្ខខ័ណ្ឌបន្ថែមលើសំណើ ឬបានកែប្រែខ្លឹមសារនៃសំណើ ស្វីការកែប្រែនោះមិនមានសុពលភាពទេ ហើយត្រូវក្លាយជាសំណើថ្មី។[10] ក្នុងករណីនេះ កិច្ចសន្យានឹងកើតឡើង ប្រសិនបើអ្នកស្នើខាងដើមធ្វើស្វីការចំពោះសំណើថ្មី ។ ឧទាហរណ៍ A ចង់លក់ឡានឲ្យ B នូវតម្លៃ១០០០០ដុល្លារ ហើយ B និយាយតបថា បើឡាននេះបាញ់ថ្នាំថ្មី គាត់នឹងទិញឡានោះ ។ បើ A យល់ព្រមបាញ់ថ្នាំថ្មី នោះកិច្ចសន្យាទិញលក់ឡានរវាង A និង B កើតមាន ។

[9] មាត្រា ៣៤១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[10] មាត្រា ៣៤២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ប្រសិនបើស្វីការដែលមានដាក់ល័ក្ខខ័ណ្ឌ ឬការកែប្រែទៅនឹងសំណើ ដោយមិនធ្វើឲ្យមានកែប្រែសារធាតុនៃសំណើទេ ស្វីការនោះមានសុពលភាពបាន លុះត្រាតែអ្នកស្នើដែលបានទទួលស្វីការនោះមិនតវ៉ាភ្លាមៗ ។

## ១.៨. ការបង្កើតកិច្ចសន្យាដោយសកម្មភាពដែលត្រូវបានចាត់ទុកថាជាស្វីការ

ទោះបីជាមិនមានការបង្ហាញឆន្ទៈអំពីស្វីការចំពោះសំណើក៏ដោយ ប្រសិនបើសកម្មភាពនោះ ត្រូវបានចាត់ទុកថាជាស្វីការ សំណើដែលបានដាក់នោះមានសុពលភាពនាំឲ្យកិច្ចសន្យាកើតមានឡើង។[11] ឧទាហរណ៍ A បញ្ជាទិញល្បែងក្មេងលេងជាឡានបញ្ជាពី B ដោយប្រាប់ពីអាសយដ្ឋាននៃការផ្ញើ B មិនបានឆ្លើយតបពីការយល់ព្រមទេ តែបានផ្ញើទំនិញនោះទៅអាសយដ្ឋានរបស់ A ករណីនេះកិច្ចសន្យាទិញលក់ឡានបញ្ជាកើតមាន ។

## ១.៩. ការដកសំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់

ចំពោះសំណើដែលផ្សាយជាសាធារណៈទៅកាន់សាធារណជន វាអាចត្រូវបានដកវិញបានតាមរយៈការផ្សាយជាសាធារណៈដែរ។[12] ឧទាហរណ៍ A បានផ្សាយដំណឹងពីការលក់ដីមួយកន្លែងតម្លៃ២០០០០ដុល្លារ តាមរយៈកាសែតរស្មីកម្ពុជានៅថ្ងៃទី២ ខែឧសភា ។ ក្រោយមក A ដូរចិត្តឈប់លក់ដីនោះវិញ ។ A ត្រូវផ្សាយជាសាធារណៈនៅកាសែតរស្មីកម្ពុជាអំពីការឈប់លក់ដីនោះវិញ ។

[11] មាត្រា ៣៤៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[12] មាត្រា ៣៤៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# ជំពូក ២
# សុពលភាព និងមោឃភាពនៃកិច្ចសន្យា

## ២.១ មូលដ្ឋានគតិយុត្តនៃសកម្មភាព

### ២.១.១ ការបង្ហាញឆន្ទៈ

ការបង្ហាញ(សកម្មភាពបង្ហាញ) ទៅខាងក្រៅនូវឆន្ទៈ (ឆន្ទៈខាងក្នុង) ដែលធ្វើឲ្យកើតឡើងនូវអានុភាពតាមផ្លូវច្បាប់ ហៅថាការបង្ហាញឆន្ទៈ ។ ដូចនេះ អ្នកដែលបានបង្ហាញឆន្ទៈ ហៅថាអ្នកបង្ហាញ ឆន្ទៈ។ ឧទាហរណ៍ ឆន្ទៈដែលបានបង្ហាញទៅខាងក្រៅ (ដោយការនិយាយផ្ទាល់មាត់ ឬដោយការសរសេរលើក្រដាសជាដើម) ថាចង់លក់របស់អ្វីមួយ ឬទិញរបស់អ្វីមួយ គឺជាការបង្ហាញឆន្ទៈ។ មានន័យថា ឆន្ទៈមុនគឺជាឆន្ទៈរបស់អ្នកលក់ រីឯឆន្ទៈក្រោយគឺជាឆន្ទៈរបស់អ្នកទិញ ។

### ២.១.២ កិច្ចសន្យា

កិច្ចសន្យាគឺជាភាពត្រឹមត្រូវនៃការបង្ហាញឆន្ទៈពីរដែលមកពីទិសផ្ទុយគ្នា។ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ពាក្យថា ការលក់ទិញ ឬកិច្ចសន្យាលក់ទិញត្រូវបានប្រើប្រាស់ជាប្រចាំ។ ក្រៅពីការលក់ទិញក៏មានកិច្ចសន្យាប្រភេទផ្សេងទៀតដូចជា ភតិសន្យា (ការជួល ឬការឲ្យជួល ដោយអ្នកជួលត្រូវបង់ប្រាក់ឈ្នួល) កិច្ចសន្យាខ្ចីបរិភោគ(ការខ្ចី និងការឲ្យខ្ចីប្រាក់ជាដើម)។

សកម្មភាពដែលបង្កើតឲ្យមានអានុភាពតាមផ្លូវច្បាប់ មិនកម្រិតត្រឹមតែកិច្ចសន្យាប៉ុណ្ណោះទេ។ ឧទាហរណ៍ ក្នុងករណីដែលអ្នកឲ្យខ្ចី មិនតម្រូវឲ្យអ្នកខ្ចី បង់ប្រាក់មកខ្លួនវិញជាដើម ទោះបីជាមិនមានការព្រមព្រៀងពីអ្នកខ្ចីក៏ដោយ ក៏អានុភាពលើកលែងបំណុលកើតមានផងដែរ ។ មានន័យថា មានការបង្ហាញឆន្ទៈរបស់បុគ្គលតែម្នាក់ ក៏បង្កើតឲ្យមានអានុភាពតាមផ្លូវច្បាប់ដែរ។ សកម្មភាពបែបនេះ ហៅថាសកម្មភាពឯកតោភាគី។ ការលើកលែងបំណុល ឬការលុបចោលនូវកិច្ចសន្យាជាដើម គឺជាឧទាហរណ៍នៃសកម្មភាពឯកតោភាគីនោះ។

ដូចនេះ នៅពេលបង្កើតកិច្ចសន្យា ភាគីទាំងពីរនឹងត្រូវចងដោយអត្ថន័យនៃកិច្ចសន្យានោះ និងករណីកិច្ច។ ឧទាហរណ៍ នៅក្នុងកិច្ចសន្យាលក់ទិញ អ្នកលក់មានករណីកិច្ចប្រគល់កម្មវត្ថុទៅឲ្យអ្នកទិញ ហើយអ្នកទិញ មានករណីកិច្ចសន្យាប្រគល់ប្រាក់ទៅឲ្យអ្នកលក់។ ប៉ុន្តែ ក្នុងករណីជាក់លាក់មួយចំនួន ចាំបាច់ត្រូវបដិសេធលើអានុភាពរបស់កិច្ចសន្យា។ ឧទាហរណ៍ ករណីដែលអត្ថន័យនៃកិច្ចសន្យានោះប្រឆាំងនឹងផលប្រយោជន៍របស់ប្រជាជាតិទាំងមូល និងករណីដែលចាំបាច់ត្រូវការពារភាគីជាដើម។

វិធីសាស្ត្រដើម្បីធ្វើការបដិសេធអានុភាពនៃកិច្ចសន្យានៅក្នុងករណីបែបនេះ គឺមោឃភាព និងការលុបចោលជាទូទៅ ករណីភាគច្រើនតម្រូវឲ្យធ្វើការបដិសេធអានុភាពនៃកិច្ចសន្យា តាមមោឃភាពជាជាងតាមការលុបចោល។

ភាពខុសគ្នារវាងចំណុចទាំងពីរ ត្រូវបានបង្ហាញដោយភាពខុសគ្នាដូចខាងក្រោម ៖

- តើអ្នកណាអាចធ្វើការអះអាងបាន ?
- អាចផ្តល់សច្ចានុម័តបានឬទេ ?
- អាចកម្រិតពេលវេលាដែរឬទេ ?

### ២.១.៣ និយមន័យសកម្មភាព

សកម្មភាពដែលសំដៅដល់មោឃភាព និងការលុបចោល គឺសំដៅទៅលើកិច្ចសន្យា ឬសកម្មភាព ឯកត្តោភាគី។ សកម្មភាពឯកត្តោភាគី គឺ ឧទាហរណ៍ ការទូទាត់ការលើកលែងជាដើម ។[13]

## ២.២ បញ្ញត្តិស្តីពីមោឃភាពនៃកិច្ចសន្យា

### ២.២.១ ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ

(អំពីបញ្ញត្តិដែលអនុវត្តដោយបង្ខំ និងបញ្ញត្តិដែលអនុវត្តតាមការស្ម័គ្រចិត្ត)

ដើមឡើយក្រមរដ្ឋប្បវេណីគឺ បង្កើតឡើង ដើម្បីដោះស្រាយជម្លោះនៃសកម្មភាពសេដ្ឋកិច្ចរវាងប្រជាជន មិនមែនដើម្បីកំណត់ទំនាក់ទំនងរវាងរដ្ឋ និងប្រជាជននោះទេ ។ ហេតុនេះឧទាហរណ៍ថាទោះជាមានកិច្ចសន្យា ដែលមានអត្ថន័យប្រឆាំងនឹងបទបញ្ញត្តិនៃក្រមរដ្ឋប្បវេណីក៏ដោយ ប្រសិនបើភាគីទាំងសងខាងមានការពេញចិត្តនោះនឹងក្លាយទៅជាគោលការណ៍ មានប្រសិទ្ធភាព ។

ឧទាហរណ៍ ក្នុង មាត្រា៥១៨[14] បានចែងថា "អ្នកលក់អាចរំលាយកិច្ចសន្យាលក់ទិញ ដោយសងប្រាក់ស្មើនឹង២ដងនៃប្រាក់កក់ទៅអ្នកទិញ"។ ប៉ុន្តែ ប្រសិនបើភាគីទាំងពីរ អ្នកលក់ នឹងអ្នកទិញមានការសន្យាដោយការពេញចិត្តថា "កិច្ចសន្យាអាចរំលាយបានដោយ អ្នកលក់សងប្រាក់ស្មើនឹង៣ដង នៃប្រាក់កក់ទៅអ្នកទិញ" ក៏អាចធ្វើបានដែរ ។ ព្រោះទោះបី ជាទទួលស្គាល់កិច្ចសន្យាបែបនេះក៏ដោយ ក៏មិនបង្កការរំខានដល់នរណាម្នាក់ឡើយ ។ ការណ៏ដែល ភាគីទាំងពីរបដិសេធការអនុវត្ត ដោយការព្រមព្រៀងបែបនេះហៅថា បញ្ញត្តិដែលអនុវត្តតាមការស្ម័គ្រចិត្ត ។

ប៉ុន្តែ មិនមែនមានន័យថា គ្រប់បញ្ញត្តិទាំងអស់របស់ក្រមរដ្ឋប្បវេណីសុទ្ធតែជាបញ្ញត្តិដែលអនុវត្តតាមការស្ម័គ្រចិត្តនោះទេ។ នៅក្នុងក្រមរដ្ឋវេណីក៏មានបទបញ្ញត្តិសម្រាប់ជា ប្រយោជន៍ដល់ប្រជាជនទាំងអស់ដែរ។ ឧទាហរណ៍ មាត្រា ១៣៥[15] បានចែងថា "ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយព្រមព្រៀង មិនមានអានុភាពបើមិនមានការចុះបញ្ជី"។ នេះជាការធានាសុវត្ថិភាពនៃរាល់កិច្ចការជំនួញ អចលនវត្ថុទាំងអស់ ដោយយកការចុះបញ្ជីមកធ្វើជាល័ក្ខខ័ណ្ឌប្រសិទ្ធិភាព។ មានន័យថា បទបញ្ញត្តិនេះ មិនមែនគ្រាន់តែជាលក្ខណៈវិនិច្ឆ័យសម្រាប់ដោះស្រាយជម្លោះរវាងគូភាគីទេ វាជាបញ្ញត្តិមានមុខងារសម្រាប់ការប្រព្រឹត្តទៅ ដ៏ត្រឹមត្រូវនៃប្រព័ន្ធរបស់រដ្ឋ ដែលហៅថាប្រព័ន្ធចុះបញ្ជី។ ប្រសិនបើមានការបង្កើតកិច្ចសន្យា ដោយផ្អែកលើ ការព្រមព្រៀង រវាងគូភាគីថា "មិនបាច់ធ្វើការផ្ទេរការ

[13] មាត្រា ៣៥៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[14] មាត្រា៥១៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[15] មាត្រា១៣៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ចុះបញ្ជី គ្រាន់តែផ្ទេរកម្មសិទ្ធ" នោះការផ្ទេរកម្មសិទ្ធិនឹង មិនត្រូវបានបង្ហាញក្នុងការចុះបញ្ជី ហើយប្រព័ន្ធចុះបញ្ជីនឹងត្រូវបាត់បង់មុខងារ ។ មានន័យថា នឹងបង្កការរំខានដល់សាធារណៈជន។ ដូច្នេះឧទាហរណ៍ បើមានការព្រមព្រៀងរវាងគូភាគីក៏ដោយ មិនអាចបង្កើតកិច្ចសន្យាដែលមានអត្ថន័យប្រឆាំងនឹង មាត្រា១៣៥បានទេ ។ កិច្ចសន្យាបែបនេះ ទុកជាមោឃភាព ។ បទបញ្ញត្តិបែបនេះ ហៅថា បញ្ញត្តិដែលអនុវត្តដោយបង្ខំ ។

ដើម្បីដឹងថា បទបញ្ញត្តិមួយជា បញ្ញត្តិដែលអនុវត្តតាមការស្ម័គ្រចិត្ត ឬជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ ចាំបាច់ត្រូវធ្វើការវិនិច្ឆ័យដោយអាស្រ័យលើគោលបំណង និងគោលដៅរបស់បទបញ្ញត្តិនោះ។ ជាទូទៅ ក្នុងផ្នែកសិទ្ធិលើបំណុលមានបញ្ញត្តិដែលអនុវត្តតាមការស្ម័គ្រចិត្តច្រើន ហើយក្នុងផ្នែកសិទ្ធិប្រត្យក្ស និងញាតិមានបញ្ញត្តិដែលអនុវត្តដោយបង្ខំច្រើន។

### ២.២.២ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ

(បញ្ញត្តិផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈនិងទំនៀមទំលាប់ល្អ)[16]

ករណីដែលA ស្នើសុំឲ្យ B សម្លាប់ C ដោយសន្យាថាឲ្យប្រាក់រង្វាន់កិច្ចសន្យាបែបនេះគឺ ផ្ទុយសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ។ មោឃភាពនៃសកម្មភាពគតិយុត្តនេះបានចែងថា រដ្ឋមិនទទួលស្គាល់នូវការអនុវត្តន៍ សកម្មភាពគតិយុត្តបែបនេះទេ។ ការស្នើសុំឲ្យធ្វើឃាតមនុស្សបែបនេះ គឺ A មិនអាចអនុវត្តសិទ្ធិទាមទារឲ្យ B សម្លាប់ C បានទេ ហើយ B ទៀតសោត ក៏មិនអាចទាមទារឲ្យ A បង់ប្រាក់ឈ្នួលសម្លាប់ទៅតាមកិច្ចសន្យានៅក្រោយពេលខ្លួនបានសម្លាប់ C ហើយនោះដែរ។ សរុបមកមាត្រា ៣៥៤ មោឃភាពសកម្មភាពដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ គឺដើម្បីរក្សាសីលធម៌សង្គម និងសណ្តាប់ធ្នាប់ប្រទេស។ ប្រសិនបើវត្ថុ ឬប្រាក់ត្រូវបានផ្តល់ជាតាវកាលិករួចហើយ តាមរយៈកិច្ចសន្យាមោឃភាពជាគោលការណ៍តាវកាលិកនោះនឹងក្លាយទៅជាសេចក្តីចម្រើនឥតហេតុរបស់ភាគីម្ខាងទៀត ហើយភាគីដែលបានអនុវត្តអាចធ្វើការអះអាងអំពីមោឃភាពនោះ ហើយអាចទាមទារឲ្យធ្វើបដិទាននូវស្ថានភាពដើម។[17] ប៉ុន្តែប្រសិនមោឃភាពនៃកិច្ចសន្យានោះដោយសារតែភាពផ្ទុយនឹង សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ ទោះបីជាវត្ថុ ឬត្រូវបានផ្តល់ជាតាវកាលិកហើយក៏ដោយ ក៏មិនអាចទាមទារឲ្យសងមកវិញបានដែរដោយសារជាតាវកាលិក ដោយមូលហេតុខុសច្បាប់ (ម៣៥៤)។

### ២.២.៣ ផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារដោយច្បាប់

ជាគោលការណ៍ មតកសាសន៍ ដែលមិនស្របទៅនឹងទម្រង់ ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណីត្រូវចាត់ទុកមោឃៈនៅក្នុងករណីនេះជនណាក៏អាចអះអាងពីមោឃភាពបានដែរ។[18] ទន្ទឹមនឹងនេះដែរ ក្រមរដ្ឋប្បវេណីក៏បានបញ្ញត្តិថា កិច្ចសន្យាដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតដែលត្រូវបានធ្វើឡើងដោយមានការឃុបឃិត

[16] មាត្រា៣៥៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[17] មាត្រា៧៣៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[18] មាត្រា១១៧០ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ជាមួយភាគីម្ខាងទៀតត្រូវចាត់ទុកជាមោឃៈ។[19] ជាងនេះទៅទៀត គឺមានគំនិតស្រដៀងគ្នាទៅនិងមោឃភាពនៅក្នុងក្រមរដ្ឋប្បវេណីដែរ បានចែងថា នៅក្នុងករណីនៃការតំណាងដោយគ្មានសិទ្ធិ សកម្មភាពរបស់ជន ដែលជាអ្នកតំណាងនេះ គឺមិនបង្កើតអនុភាពចំពោះម្ចាស់សិទ្ធិឡើយ។ មូលហេតុ គឺមិនមានអ្នកណាម្នាក់ ត្រូវអនុវត្តកាតព្វកិច្ចដោយមិនផ្អែកលើឆន្ទៈរបស់ខ្លួនឡើយ។[20] ប្រសិនបើបុគ្គល ដែលបានធ្វើសកម្មភាពក្នុងនាម អ្នកតំណាង ប៉ុន្តែខ្លួនមិនមែនសិទ្ធិតំណាង ដូចនេះវាមិនមានមូលដ្ឋានតាមច្បាប់ ដែលត្រូវធ្វើសកម្មភាពក្នុងនាមជាអ្នកតំណាង ត្រូវមោឃៈប៉ុន្តែម្ចាស់សិទ្ធិអាច ផ្តល់សច្ចានុមតិលើសកម្មភាពនោះបាន។ ដូចនេះ ចែងអំពីមោឃភាពនៅក្នុងករណីនៃការតំណាងដោយគ្មានសិទ្ធិ ប៉ុន្តែគំនិតរបស់វា គឺមានលក្ខណៈខុសគ្នា។[21]

### ២.២.៤ ការបង្ហាញឆន្ទៈមិនពិត

#### ២.២.៤.១ ទំនាក់ទំនងរវាងគូភាគីនៃការបង្ហាញឆន្ទៈមិនពិត

តើមានល័ក្ខខ័ណ្ឌអ្វីខ្លះ ក្នុងការអនុវត្តមាត្រា ៣៥៣ កថាខណ្ឌទី១?[22] ការបង្ហាញឆន្ទៈមិនពិត គឺឧទាហរណ៍ដូចជាករណី (ក) មានគំនិតលាក់បាំងនូវទ្រព្យសម្បត្តិរបស់ខ្លួន ហើយបានពិក្សាជាមួយ (ខ) ដែលជាភរិយា ដោយឃុបឃិតគ្នាធ្វើប្រទានកម្មទ្រព្យសម្បត្តិរបស់គាត់ទៅ (ខ) ដែលតាមការពិតទៅគាត់គ្មានឆន្ទៈធ្វើប្រទានកម្មបែបនោះឡើយ ពោលគឺជាករណីដែលបានបង្ហាញចេញមក ថ្វីបើគ្មានឆន្ទៈដូចដែលបានបង្ហាញចេញមកក៏ដោយ។ ករណីបែបនេះ គឺមិនមែនតែអ្នកបង្ហាញឆន្ទៈតែម្នាក់ឯងទេគឺភាគីម្ខាងទៀតក៏បានដឹងដែរថា អ្នកបង្ហាញឆន្ទៈមិនមានឆន្ទៈពិតដូចដែលបានបង្ហាញចេញមកនោះទេ។ ការបង្ហាញឆន្ទៈបែបនេះ គឺជាការបង្ហាញឆន្ទៈមិនពិតរវាងគូភាគី ហើយដែលច្បាប់បញ្ញត្តថាត្រូវទុកមោឃៈ។[23]

ការពារតតិយជនដែលសុចរិត ក្នុងករណីដែលតតិយជនមិនដឹងអំពីអង្គហេតុស្តីពីការបង្ហាញឆន្ទៈមិនពិតនោះ (មានន័យថាសុចរិត) ដូច្នេះមិនអាចតតាំងដោយផ្អែកលើមោឃភាពបានទេ។[24]

**ករណីសិក្សាទី១**

A ជំពាក់បំណុលជាច្រើន ហើយបារម្ភខ្លាចម្ចាស់បំណុលដាក់ពាក្យសុំអនុវត្តដោយបង្ខំទៅលើទ្រព្យសម្បត្តិរបស់ខ្លួន។ ហេតុនេះ ដើម្បីជៀសផុតពីការអនុវត្តដោយបង្ខំទៅលើដី X ដែលជាកម្មសិទ្ធិរបស់ខ្លួន A ក៏សម្រេចក្លែងធ្វើជាលក់ដីទៅឲ្យ B ដែលជាមិត្តភក្តិ។ ដូចនេះ A បានទៅពិក្សាជាមួយ B ហើយបានផ្ទេរការចុះបញ្ជីកម្មសិទ្ធិលើដី X ឲទៅ B។ ក្រោយមក A បានសងបំណុលទាំងអស់ទៅឲ្យម្ចាស់បំណុលរួចរាល់ ហើយលែងមានការបារម្ភពីការអនុវត្តដោយបង្ខំដែរ ក៏បាននិយាយទៅកាន់ B ឲ្យផ្ទេរការចុះបញ្ជីកម្មសិទ្ធិលើដី X មកឲខ្លួនវិញ។ ប៉ុន្តែB មិនព្រម

[19] មាត្រា៣៥៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[20] មាត្រា៣៦៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[21] មាត្រា៣៥៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[22] មាត្រា៣៥៣ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[23] មាត្រា៩៤ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[24] មាត្រា៩៤ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ផ្ទេរការចុះបញ្ជីឲ្យ A វិញទេ។ តើ A អាចអះអាងអំពីមោឃភាពនៃកិច្ចសន្យារវាង A និង B ផ្ទេរការចុះបញ្ជីមកខ្លួនវិញ ដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតបានដែរឬទេ។ A អាចអះអាងអំពីមោឃភាពនៃកិច្ចសន្យារវាង A និង B និងទាមទារឲ្យ B ផ្ទេរការចុះបញ្ជីមកខ្លួនវិញ ដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតបាន។[25]

### ២.២.៤.២ ការបង្ហាញឆន្ទៈមិនពិត និងតតិយជន

មានល័ក្ខខ័ណ្ឌខ្លះ ដើម្បីឲតតិយជនអះអាងអំពីសុពលភាពនៃកិច្ចសន្យាដោយផ្អែកតាមមាត្រា ៣៥៣ កថាខណ្ឌទី២ ចំពោះបុគ្គលដែលធ្វើការបង្ហាញឆន្ទៈមិនពិត។ តែចំពោះ មោឃៈភាពនៃកិច្ចសន្យាដែលបានកំណត់ក្នុងកថាខណ្ឌទី១នៃមាត្រា ៣៥៣ មិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយយកកិច្ចសន្យាដែលផ្អាកលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានឡើយ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តិឡើយចំពោះករណីដែលតតិជននោះជាជនទុច្ចរិត ឬមិនបានដឹងអំពីការបង្ហាញនូវឆន្ទៈមិនពិតដោយកំហុសធ្ងន់ធ្ងរ។

គោលគំនិតនៃមាត្រា ៣៥៣ កថាខណ្ឌទី២ គឺការពារចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ផ្សេងទៀត។

**ករណីសិក្សាទី ២**

ដូចគ្នានឹងករណីសិក្សាទី១៥ដែរ B លក់ដី X ទៅឲ្យ C ហើយបានផ្ទេរការចុះបញ្ជីកម្មសិទ្ធិទៅឲ្យ C។ C មិនបានដឹងថាកិច្ចសន្យាទិញលក់រវាង A និង B ជាការបង្ហាញឆន្ទៈមិនពិតទេ ហើយក៏មិនមានកំហុសចំពោះការមិនដឹងនោះដែរ។ ប្រសិនបើ A ទាមទារឲ្យ C ផ្ទេរការចុះបញ្ជីមកឲ្យ A វិញ តើ C អាចបដិសេធបានដែរ ឬទេ?

C អាចបដិសេធបាន ព្រោះ C មិនបានដឹងថាកិច្ចសន្យាទិញលក់រវាង A និង B ជាការបង្ហាញឆន្ទៈមិនពិតទេហើយក៏មិនមានកំហុសចំពោះការមិនដឹងនោះដែរ[26]។

---

[25] មាត្រា៩៤ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[26] មាត្រា៣៥៣ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# ជំពូក ៣
# សុពលភាព និងការលុបចោលនៃកិច្ចសន្យា

## ៣.១ សកម្មភាពដែលអាចលុបចោលបាន

បើសកម្មភាពមួយជាមោឃភាព ទោះជាភាគីមិនអះអាងមោឃភាព ក៏តាមសត្យានុម័តខាងក្រៅ គឺជាមោឃភាព។[27] ម៉្យាងវិញទៀត សកម្មភាពដែលអាចលុបចោលបាន មានសុពលភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ។

ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានលុបចោល សកម្មភាពនោះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង។ មានន័យថា ការលុបចោល មានអានុភាពប្រតិសកម្ម។

ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានផ្តល់សច្ចានុមតិសកម្មភាពនោះនឹងត្រូវមានសុពលជាស្ថាពរ ។

មាត្រានេះបានបញ្ញត្តិពីមោឃភាព និងការលុបចោលដើម្បីបដិសេធចោលសុពលនៃសកម្មភាពគតិយុត្ត។ បញ្ញត្តិនេះចង់រំលេច ឲ្យអ្នកច្បាប់មើលឃើញពីភាពខុសគ្នា រវាងមោឃភាព និងការលុបចោល ។ មោឃភាពសំដៅទៅលើការដែលសកម្មភាពគតិយុត្តមួយ ត្រូវបានចាត់ទុកថាមិនមានអត្ថិភាព តាំងពីដំបូងហើយអ្នកណាក៏អាចអះអាងចំពោះគ្រប់បុគ្គលបានដែរ។ ម៉្យាងទៀត មិនមានការកំណត់ពីកំឡុងពេល ដែលអាចអះអាងពីអំពីមោឃភាពទេ។ ដោយឡែកចំពោះការលុបចោលវិញ គឺសកម្មភាពគតិយុត្តមួយមាន សុពលភាព តាំងពីដំបូង ក៏ប៉ុន្តែនៅពេលដែលត្រូវបានលុបចោលគឺត្រូវបានចាត់ទុកថា មិនមានសុពលភាពតាំងពីដំបូង។ នៅពេលដែលត្រូវបានលុបចោល គឺវានឹងក្លាយទៅជាដូចគ្នាជាមួយនិងមោឃភាពដែរ ក៏ប៉ុន្តែអ្វីដែលខុសគ្នា ខ្លាំងជាមួយនិងមោឃភាព គឺជាសកម្មភាពនោះមានសុពលភាពតាំងពីមុនរហូតមកត្រឹម ពេលដែលត្រូវបានលុបចោល។ លើសពីនេះទៀតគឺមានការកំណត់វិសាលភាព នៃអ្នកដែលអាចលុបចោលបាន និងការកំណត់ថា ប្រសិនបើមិនបានលុបចោលក្នុងកំឡុងពេល៣ឆ្នាំ គឺចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិ គឺមិនអាចលុបចោលបានឡើយ ។

សរុបមក ចំពោះមោឃភាព និងការលុបចោលអាចនិយាយបានថា មោឃភាពគឺផ្តល់នូវឥទ្ធិពលដែលមានអានុភាពខ្លាំងក្លាជាង។

## ៣.២. អ្នកមានសិទ្ធិលុបចោល

អ្នកមានសិទ្ធិលុបចោលមានដូចខាងក្រោមៈ[28]

ករណីការបង្ហាញឆន្ទៈមានវិការៈ (ការភាន់ច្រឡំ ,ការឆបោក ,អំពើគេងចំណេញហួសហេតុជាដើម )៖

- អ្នកបង្ហាញឆន្ទៈ
- អ្នកតំណាងដែលច្បាប់បានកំណត់

[27] មាត្រា៣៥៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[28] មាត្រា៣៥៩ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- សន្តតិជន
- អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យា

ករណីកង្វះសមត្ថភាពខាងឆន្ទៈ ឬការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព (ម៣៥៩.២)។

- អ្នកបង្ហាញឆន្ទៈ
- អ្នកតំណាងដែលច្បាប់បានកំណត់
- ហិតូបត្ថម្ភកៈ
- សន្តតិជន
- អច្ច័យលាភីសកល

## ៣.៣. បញ្ញត្តិស្តីពីការលុបចោលនៃកិច្ចសន្យា

### ៣.៣.១ ការភាន់ច្រឡំ

**ក) និយមន័យ**

១) ការភាន់ច្រឡំ មានន័យថា គឺជាការបង្ហាញនូវឆន្ទៈទៅលើកិច្ចសន្យាដោយការយល់ច្រឡំអំពីខ្លឹមសារនៃកិច្ចសន្យា។

២) ការយល់ខុសដោយខ្លួនឯងដោយមិនមានអ្នកណាមួយមកបំភាន់ឡើយ។

៣) គឺជាស្ថានភាពមួយដែលធាតុអត្តនោម័តខាងក្នុង ខុសពីភាពសត្យានុម័តខាងក្រៅ។

**ខ) ដំណាក់កាលនៃការបង្ហាញឆន្ទៈ**

- ប្រភេទនៃការភាន់ច្រឡំមានដូចខាងក្រោម៖
    - ការភាន់ច្រឡំទៅលើមូលហេតុ[29]
    - ការភាន់ច្រឡំទៅលើខ្លឹមសារ[30]
        - ចំណុចសំខាន់នៃកិច្ចសន្យាមើលពីខាងក្រៅ
        - ចំណុចនៃកិច្ចសន្យាដែលភាគីម្ខាងយល់ថាសំខាន់
    - ការភាន់ច្រឡំទៅលើការបង្ហាញ
        - ចំណុចសំខាន់នៃកិច្ចសន្យាមើលពីខាងក្រៅ
        - ចំណុចនៃកិច្ចសន្យាដែលភាគីម្ខាងយល់ថាសំខាន់
    - ការភាន់ច្រឡំរួម

[29] មាត្រា៣៤៦ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[30] មាត្រា៣៤៦ កថាខណ្ឌទី១-២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ឧទាហរណ៍១អំពីការភាន់ច្រឡំទៅលើមូលហេតុ** (ក) បានបង្កើតកិច្ចសន្យាទិញដីពី (ខ) ក្នុងតម្លៃ ១០០០០០ដុល្លារអាមេរិក ដោយខ្លួនយល់ថា ទៅថ្ងៃមុខនឹងមានសាងសង់ផ្សារទំនើបនៅជិតទីនោះ។ តាមពិតនៅជិតដីនោះមិនមានគម្រោងសាងសង់ផ្សារទំនើបទេ។ **ករណីនេះជាការភាន់ច្រឡំលើមូលហេតុ។**

**ឧទាហរណ៍២ អំពីការភាន់ច្រឡំលើខ្លឹមសារ** (ក) យល់ថាដីរបស់ (ខ) មានទំហំ៥០០០ម៉ែតការ៉េ ក៏បានបង្កើតកិច្ចសន្យាទិញដីនោះ ក្នុងតម្លៃ១០០០០០ដុល្លារអាមេរិក។ តាមពិត ដីនោះមានទំហំតែ៣០០០ម៉ែត្រការ៉េតែប៉ុណ្ណោះ។ **នេះជាការភាន់ច្រឡំលើខ្លឹមសារ។**

**ឧទាហរណ៍៣ អំពីការភាន់ច្រឡំលើការបង្ហាញ** ភាគី (ក) បានដាក់ស្លាកលក់ដីមួយកន្លែងក្នុងតម្លៃ ១០០០០ដុល្លារអាមេរិក។ ក្រោយមកភាគី (ខ) យល់ព្រមទិញដីនោះហើយក៏បានផ្ញើសារមកសុំទិញដីភាគី (ក) ដោយសរសេរច្រឡំតម្លៃថា ១០០០០០ដុល្លារអាមេរិក។ ភាគី (ក) បានផ្ញើសារត្រឡប់ទៅវិញ ថាយល់ព្រមលក់ដីនោះ។ **នេះជាការភាន់ច្រឡំលើការបង្ហាញ។**

### ៣.៣.១.១ ការភាន់ច្រឡំក្នុងកិច្ចសន្យា

**ល័ក្ខខ័ណ្ឌនៃការភាន់ច្រឡំ៖**[31]

ក) ភាគីមានការភាន់ច្រឡំ

ខ) ចំណុចដែលភាន់ច្រឡំជាចំណុចសំខាន់ក្នុងកិច្ចសន្យា

គ) ភាគីម្ខាងទៀតបានដឹងពី ភាគីដែលមានការភាន់ច្រឡំ

កថាខ័ណ្ឌទី១ ចែងថា ភាគីដែលមានការភាន់ច្រឡំត្រូវបានអនុញ្ញាតឲលុបចោលកិច្ចសន្យាក្នុងលក្ខខ័ណ្ឌដែលមានការភាន់ច្រឡំអំពីចំណុចសំខាន់នៃកិច្ចសន្យា ហើយភាគីម្ខាងទៀតអាចដឹងថាមានការភាន់ច្រឡំ។

**តើចំណុចសំខាន់ៗនៃកិច្ចសន្យាជាអ្វី?** វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ គឺជាចំណុចសំខាន់នៃកិច្ចសន្យាលក់។

**ឧទាហរណ៍** (ក) បានបង្កើតកិច្ចសន្យាទិញដីពី (ខ) ដោយខ្លួនយល់ថា ទៅថ្ងៃមុខនឹងមានសាងសង់ផ្សារទំនើបនៅជិតទីនោះ។ ប៉ុន្តែនៅថ្ងៃបន្ទាប់ភាគី (ក) បានដឹងថាមិនមានការសាងសង់ផ្សារទំនើបអ្វីទេនៅជិតដីនោះទៅថ្ងៃខាងមុខ ដូច្នេះហើយភាគី (ក) បានលុបចោលកិច្ចសន្យាទិញដីនោះជាមួយភាគី (ខ)។

ដូច្នេះ ដី គឺជាកម្មនៃកិច្ចសន្យាគឺជាចំណុចសំខាន់នៃកិច្ចសន្យា។

**ករណីសិក្សាទី១**

A បានទទួលការណែនាំទៅមើលដី X និងដី Y នៅក្នុងទីក្រុងភ្នំពេញពីអ្នកប្រកបអាជីវកម្មអចលនវត្ថុ B។ នៅពេលនោះ A បាននិយាយទៅកាន់ B ថា «ខ្ញុំចាប់អារម្មណ៍ដី X ប៉ុន្តែខ្ញុំគិតថាទៅពិភាក្សាជាមួយប្រពន្ធសិន» ។ A ត្រលប់ទៅផ្ទះវិញក៏បានពិក្សាជាមួយប្រពន្ធ ហើយប្រពន្ធក៏បានយល់ព្រមដែរ។ ហេតុដូច្នេះA បានផ្ញើ Email ទៅ

[31] មាត្រា៣៤៦ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

B ថា «ដោយសារប្រពន្ធរបស់ខ្ញុំក៏បានយល់ព្រមដែរ ខ្ញុំនឹងទិញដី Y តាមគម្រោង» នៅពេលនោះ A បានសរសេរ ច្រឡំនៅត្រង់កន្លែងដី X ទៅជាដី Y ទៅវិញ។ ហើយ A ក៏បានបង្កើតកិច្ចសន្យាជាមួយ B។ ថ្ងៃបន្ទាប់ A បានដឹង ខ្លួនថាច្រឡំ តើ A អាចលុបចោលកិច្ចសន្យាលក់ទិញ ដោយមូលហេតុភាន់ច្រឡំបានដែរឬទេ? ក្នុងករណីសិក្សាទី ១នេះ A អាចលុបចោលកិច្ចសន្យាលក់ទិញ ដោយមូលហេតុភាន់ច្រឡំបាន។[32]

### ៣.៣.១.២ ការភាន់ច្រឡំអំពីហេតុសំខាន់ចំពោះភាគីម្ខាង

**ល័ក្ខខ័ណ្ឌនៃការភាន់ច្រឡំ៖**[33]

ក) ភាគីមានការភាន់ច្រឡំ

ខ) ភាគីដែលភាន់ច្រឡំ មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬចំណុចដែលខ្លួនយល់ឃើញថា សំខាន់ក្នុងការបង្កើតកិច្ចសន្យា។

គ) ភាគីម្ខាងទៀតបានដឹងពីភាគី ដែលភាន់ច្រឡំ ហើយក៏ដឹងថា ចំណុចដែលភាគីភាន់ច្រឡំជាចំណុចសំខាន់របស់ភាគីភាន់ច្រឡំ។

កថាខណ្ឌទី ២ ចែងអំពីករណីដែលអ្នកបង្ហាញឆន្ទៈ មានការភាន់ច្រឡំអំពីចំណុចដែលខ្លួនឯងយល់ ដោយអត្តនោម័តថាសំខាន់។

**ត្រូវចែកជាពីរករណីដូចខាងក្រោម៖**

**ករណីទី១**

អ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំនៅផ្នែកណាមួយនៃកិច្ចសន្យា ដែលជាធម្មតាមិនសំខាន់ទេទៅតាម ប្រភេទនៃកិច្ចសន្យា ប៉ុន្តែអ្នកបង្ហាញឆន្ទៈនោះយល់ឃើញខ្លួនឯងដោយអត្តនោម័តថាចំណុចសំខាន់។ ឧទាហរណ៍ ករណីនៃការលក់ទិញរថយន្ត ទោះបីជាពណ៌របស់រថយន្តជាធម្មតា មិនមែនជា ចំណុចសំខាន់នៃកិច្ចសន្យាក៏ដោយ ប៉ុន្តែបើអ្នកទិញ ចាត់ទុកថា «ពណ៌» ថាជាចំណុចសំខាន់ ក្នុងការប្រើប្រាស់របស់គាត់ អ្នកទិញអាចអនុញ្ញាតឲលុប ចោលកិច្ចសន្យាដោយហេតុផលនៃការភាន់ច្រឡំអំពីពណ៌បាន។ ប៉ុន្តែក្នុងល័ក្ខខ័ណ្ឌដែលភាគីម្ខាងទៀតអាចដឹង ថា «ពណ៌» គឺជាចំណុចសំខាន់សម្រាប់អ្នកទិញហើយអាចដឹងបានដែរថា អ្នកទិញមានការភាន់ច្រឡំ។

**ករណីទី២**

ជាករណីដែលត្រូវហៅថា «ការភាន់ច្រឡំអំពីមូលហេតុ» ឧទាហរណ៍ (ក) បង្កើតកិច្ចសន្យាជាមួយ (ខ) ដើម្បីទិញភ្នំដែលមានព្រៃឈើ ដោយមានបំណងកាប់ព្រៃឈើ ប៉ុន្តែ (ក) មិនបានដឹងថាការកាប់ដើមឈើត្រូវបាន ហាមឃាត់ទេ ដោយសារការភាន់ច្រឡំរបស់ខ្លួន។ ក្នុងករណីនេះ (ក) មានការភាន់ច្រឡំអំពីមូលហេតុ (បំណង)

[32] មាត្រា៣៤៦ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[33] មាត្រា៣៤៦ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

នៃការបង្កើតកិច្ចសន្យា ដោយអត្តនោម័ត។ ក្នុងករណីនេះ ការលុបចោលកិច្ចសន្យាត្រូវបានអនុញ្ញាត លុះត្រាតែក្នុងករណីដែលភាគីដែលមានការភាន់ច្រឡំបញ្ជាក់ថា ភាគីម្ខាងទៀត «អាចដឹង» អំពីការភាន់ច្រឡំនោះ។[34]

ចំណុចដែលយល់ឃើញថាសំខាន់នៅពេលបង្កើតកិច្ចសន្យា មូលហេតុ និងគោលបំណង។

**ករណីសិក្សាទី២**

ដូចក្នុងករណីសិក្សាទី១ដែរ A បាននិយាយទៅកាន់ B ថា «ដី X និង ដី Y ជាដីល្អ ប៉ុន្តែខ្ញុំឮថា ឆាប់ៗនេះនៅជិតដី X នឹងមានការសាងសង់ផ្សារអ៊ីអនដ៏ធំ ហេតុនេះខ្ញុំសម្រេចទិញដី X" ហើយក៏បានបង្កើតកិច្ចសន្យាលក់ទិញ។ តាមការពិត មិនមានគម្រោងសាងសង់ផ្សារអ៊ីអននោះទេ ហើយ B ក៏បានដឹងអំពីចំណុចនេះដែរ ប៉ុន្តែ B មិនបានប្រាប់ A ហើយបង្កើតកិច្ចសន្យានេះឡើងតែម្តង។ ថ្ងៃបន្ទាប់ A បានដឹងអំពីចំណុចនេះ តើA អាចលុបចោលកិច្ចសន្យាដោយមូលហេតុនៃការភាន់ច្រឡំបាន។[35]

### ៣.៣.១.៣ ការភាន់ច្រឡំរួម

ល័ក្ខខ័ណ្ឌក្នុងការអនុវត្តស្តីពី ការភាន់ច្រឡំរួមៈ[36]

ក) ភាគីទំងសងខាងមានការភាន់ច្រឡំ

ខ) ចំណុចដែលមានការភាន់ច្រឡំ គឺជាចំណុចសំខាន់ក្នុងកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា។ (**ការភាន់ច្រឡំរួម អំពីចំណុចសំខាន់នៃកិច្ចសន្យា**)ៈ

**ឧទាហរណ៍១** (ក) ជាអ្នកបើកហាងលក់សម្ភារសិក្សាមានម៉ាកល្បីៗបានតាំងលក់កាតាប ម៉ាក Monblan ដែលមានតម្លៃខ្ពស់ ហើយបានច្រឡំដាក់តាំងកាតាម៉ាក Monblan ដែលផលិតនៅប្រទេសចិនចូលជាមួយ (ខ) យល់ច្រឡំថា ជារបស់ពិត ហើយទិញក្នុងតម្លៃខ្ពស់។ ម៉ាក Monblan ពិតផលិតនៅប្រទេស អាល្លឺម៉ង់ Monblan មិនពិតផលិតនៅប្រទេសចិន គឺជាចំណុចសំខាន់ក្នុងកិច្ចសន្យា។ ក្នុងករណីនេះអ្នកលក់ (ក) និងអ្នកទិញ (ខ) មានការភាន់ច្រឡំដូចគ្នា។ ទោះបីជា (ក) មិនដឹងអំពីការភាន់ច្រឡំរបស់ (ខ) អាចលុបចោលកិច្ចសន្យានេះបាន ដែរ។

**ឧទាហរណ៍២** ប្រសិនបើភាគីទាំងពីមានការភាន់ច្រឡំអំពីចំណុចសំខាន់នៃកិច្ចសន្យា កិច្ចសន្យាអាចលុបចោលបាន ទោះបីភាគីម្ខាងគ្មានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ។ ឧទាហរណ៍ អ្នកលក់និងអ្នកទិញបានបង្កើតកិច្ចសន្យាលក់ទិញរូបភាពដែលភាគីទាំងពីរជឿជាក់ថាត្រូវបានគូរដោយវិចិត្រករល្បីឈ្មោះ ប៉ុន្តែ ក្រោយមក គេបានរកឃើញថា រូបភាពនោះមិនមែនជាស្នាដៃរបស់វិចិត្រករល្បីឈ្មោះទេ គឺជាស្នាដៃ

[34] មាត្រា៣៤៦ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[35] មាត្រា៣៤៦ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[36] មាត្រា៣៤៦ កថាខណ្ឌទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

របស់វិចិត្រករជម្មតាតែប៉ុណ្ណោះ។ ករណីនេះបើភាគីណាមួយរកឃើញការពិតបែបនេះហើយចង់លុបចោលកិច្ចសន្យាលក់ទិញវិញ អាចលុបបាន។[37]

**ឧទាហរណ៍៣** (ការភាន់ច្រឡំរួម អំពីចំណុចដែលយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា)៖ Aជាម្ចាស់សណ្ឋាគារនៅក្រុងសៀមរាប គាត់គិតថានៅទីក្រុងសៀមរាប នឹងមានការប្រគុំតន្ត្រីអន្តរជាតិល្បីមួយនៅជិតទីក្រុងនេះ ហើយនឹងមានភ្ញៀវច្រើន ដូច្នេះហើយ A ក៏បានឡើងថ្លៃជាងតម្លៃធម្មតា២ដង។ ក្រោយមកការប្រគុំតន្ត្រីត្រូវបានប្តូរទីតាំង ទៅកន្លែងផ្សេងដែលនៅឆ្ងាយពីទីនោះ។ ដើម្បីចូលរួមមើលតន្ត្រីអន្តរជាតិនោះ B ក៏បានកក់សណ្ឋាគាររបស់ A។ A និង B មិនបានដឹងអំពីការផ្លាស់ប្តូរទីតាំងនេះទេ។ ការផ្លាស់ប្តូរ ទីតាំងនៃការប្រគុំតន្ត្រីបានធ្វើឡើងមុនពេលបង្កើតកិច្ចសន្យា។ ការប្រគុំតន្ត្រីនៅទីក្រុងសៀមរាប ឬមិននៅទីនោះមិនមែនជាចំណុចនៃកិច្ចសន្យានោះទេ ប៉ុន្តែ A និង B បានគិតថាជាចំណុចសំខាន់ក្នុងការបង្កើតកិច្ចសន្យា ហើយអ្នកទាំងពីរមានការភាន់ច្រឡំអំពីចំណុចនេះ។ ទោះបីជា A មិនដឹងអំពីការភាន់ច្រឡំរបស់B ក៏ដោយ ក៏B អាចលុបចោលនូវកិច្ចសន្យានោះបានដែរ។

**ករណីសិក្សាទី៣**

ដូចក្នុងករណីសិក្សាទី២ដែរ ក្នុងករណីដែល A និង B សុទ្ធតែយល់ច្រឡំថាមានគម្រោងសាងសង់ផ្សារអ៊ីអននៅជិតដី X តើ A អាចលុបចោលកិច្ចសន្យាលក់ទិញដី X ដោយយកមូលហេតុនៃការភាន់ច្រឡំបានដែរឬទេ? ដូច្នេះ A អាចលុបចោលកិច្ចសន្យាលក់ទិញដី X ដោយយកមូលហេតុនៃការភាន់ច្រឡំ បាន។[38]

**៣.៣.១.៤ ផលវិបាក និងការលុបចោលដោយការភាន់ច្រឡំ**

**ក) អានុភាពប្រតិសកម្ម**

កិច្ចសន្យាដែលមានការភាន់ច្រឡំ អាចលុបចោលបាន ហើយសកម្មភាពដែលត្រូវបានលុបចោលនោះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង។[39]

**ខ) ការសងតាវកាលិកៈ**

ក្នុងករណីលុបចោលកិច្ចសន្យា តាវកាលិកដែលទទួលបានពីកិច្ចសន្យានឹងក្លាយជាសេចក្តីចម្រើនឥតហេតុ។[40] បើបុគ្គលដែលទទួលបានផលប្រយោជន៍មានចេតនា ឬកំហុស ចំពោះអានុភាពនៃកិច្ចសន្យាដែលត្រូវបានបាត់បង់ បុគ្គលដែលបានទទួលផលប្រយោជន៍នោះ មានករណីកិច្ចត្រូវសងផលប្រយោជន៍នោះ ដោយភ្ជាប់ជាមួយនឹងការប្រាក់។ លើសពីនេះ បើបុគ្គលដែលត្រូវបាត់បង់ផលប្រយោជន៍ទទួលការខូចខាតបុគ្គលដែល

[37] មាត្រា៣៤៦ កថាខណ្ឌទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[38] មាត្រា៣៤៦ កថាខណ្ឌទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[39] មាត្រា៣៥៨ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[40] មាត្រា៧៣៦ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

បានទទួលផលប្រយោជន៍ត្រូវទទួលខុសត្រូវលើសំណងនៃការខូចខាត។[41]

**គ) ការការពារតតិយជនះ**

ការលុបចោលកិច្ចសន្យាដោយការភាន់ច្រឡំ ក្រៅពីភាគីម្ខាងទៀតអាចអះអាងចំពោះតតិយជន បាន។ ប៉ុន្តែ ប្រសិនបើតតិយជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំនោះមិនអាចអះអាងនូវការលុបចោលចំពោះតតិយជនបានឡើយ។[42]

**តតិយជនមុនការលុបចោល**

(ក) បានលក់វត្ថុអនុស្សាវរីយ៍ឲ (ខ) ហើយ (ខ) បានលក់បន្តទៅឲគេ (គ)។ ក្រោយមកកិច្ចសន្យារវាង (ក) និង (ខ) ត្រូវបានលុបចោល។ ករណីនេះ (គ) គឺជាតតិយជនមុនពេលលុបចោលកិច្ច សន្យា។

**តតិយជនក្រោយការលុបចោល**

(ក) បានលក់វត្ថុអនុស្សាវរីយ៍ឲ (ខ) បន្ទាប់មកកិច្ចសន្យារវាង (ក) និង (ខ) ត្រូវបានលុប ចោល។ ក្រោយមក (ខ) បានលក់បន្តនៅឲ (គ)។ ករណីនេះ (គ) គឺជាតតិយជនក្រោយពេលលុបចោលកិច្ច សន្យា។

ក្នុងវាក្យខណ្ឌ២ កថាខណ្ឌ៤នៃមាត្រា៣៤៦ មិនមានបែងចែកតតិយជនមុន ឬក៏ក្រោយការលុបចោលកិច្ចសន្យានោះទេ ហេតុនេះហើយអាចធ្វើការបកស្រាយថាគឺសំដៅទៅលើតតិយជនទាំងមុននឹងក្រោយការលុបចោលកិច្ចសន្យាបាន។ ប៉ុន្តែ បើយោងតាមទ្រឹស្តីច្បាប់ ស្ថានភាពរបស់តតិយជនមុនពេលលុបចោលកិច្ចសន្យា និងតតិយជនក្រោយពេលលុបចោលកិច្ចសន្យាមានភាពខុសគ្នា ហេតុនេះហើយគួរធ្វើការបែងចែកឲដាច់ពីគ្នា។ ពាក្យថា (តតិយជន) ក្នុងវាក្យខណ្ឌ២ កថាខណ្ឌ៤ នៃមាត្រា៣៤៦ មានគំនិតមួយលើកឡើងថា សំដៅទៅលើតែតតិយជននៅមុនពេលលុបចោលកិច្ចសន្យាតែប៉ុណ្ណោះ។

**ភាពខុសគ្នាតាមគោលជំហនៃទ្រឹស្តី**

**តតិយជនមុនពេលលុបចោលកិច្ចសន្យាះ**

ទទួលរងការខូចខាតដោយសារតែអានុភាពប្រតិសកម្មនៃការលុបចោល។ ការលុបចោលគឺ ជាបញ្ហាដាច់ដោយឡែក ដូច្នេះការលុបចោល គួរការពារតាមរយៈបញ្ញាត្តិដាច់ដោយឡែក។[43]

**តតិយជនក្រោយពេលលុបចោលកិច្ចសន្យាះ**

ទទួលរងការខូចខាតដោយសារតែចុះកិច្ចសន្យាជាមួយជនដែលគ្មានសិទ្ធិ មិនមែនដោយសារតែអានុភាពប្រតិសកម្មនៃការលុបចោលនោះទេ។ ដូច្នេះ អាចពិចារណាបានថាត្រូវការពារតាមប្រព័ន្ធដែលការពារបុគ្គលដែលចុះកិច្ចសន្យាជាមួយជនដែលគ្មានសិទ្ធិ ឬក៏ជនដែលមិនមានសិទ្ធិពេញលេញជាដើម។[44]

---

[41] មាត្រា៧៣៧ កថាខណ្ឌទី២ ទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[42] មាត្រា៣៤៦ កថាខណ្ឌទី៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[43] មាត្រា៣៤៦ កថាខណ្ឌទី៤ វាក្យខណ្ឌ២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[44] មាត្រា១៣៤ ១៩៣ និង ៣៥៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

តតិយជនមុនពេលលុបចោលកិច្ចសន្យា ឧទាហរណ៍ នៅពេល (គ) ធ្វើពាណិជ្ជកម្មជាមួយ (ខ) ជាជនដែលមានសិទ្ធិ។ ប៉ុន្តែ ប្រសិនបើក្រោយមក (ក) លុបចោលកិច្ចសន្យានោះ (ខ) និងក្លាយជាបុគ្គលគ្មានសិទ្ធិតាំងពីដំបូងតាមអានុភាពប្រតិសកម្ម។

តតិយជនក្រោយពេលលុបចោលកិច្ចសន្យា ឧទាហរណ៍នៅពេលដែល (គ) ធ្វើពាណិជ្ជកម្មជាមួយ (ខ) នោះ (ខ) គឺជាជនដែលគ្មានសិទ្ធិរួចទៅហើយ។

**ការការពារតតិយជននៅក្នុងការលុបចោលដោយមូលហេតុការភាន់ច្រឡំ**[45]

ក្នុងករណីអ្នកដែលមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោលបានសកម្មភាពនោះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង។

**ការការពារតតិយជនមុនពេលលុបចោលកិច្ចសន្យាៈ**

ជនដែលសុចរិត និងគ្មានកំហុស (គ)ត្រូវទទួលបានការការពារតាមរយៈ វាក្យខណ្ឌ២ កថាខណ្ឌ៤ នៃមាត្រា៣៤៦។ សុចរិត និងគ្មានកំហុងមានន័យថា ពេលដែល (ខ) និង (គ) ចុះកិច្ចសន្យាជាមួយគ្នា (គ) មិនបានដឹងអំពីការភាន់ច្រឡំរបស់ (ក) ព្រមទាំងមិនមានកំហុសក្នុងការមិនបានដឹង។

**ការការពារតតិយជនក្រោយពេលលុបចោលកិច្ចសន្យាៈ**

ក្នុងវាក្យខណ្ឌ២ កថាខណ្ឌ៤ មាត្រា៣៤៦ មិនបានបដិសេធច្បាស់លាស់អំពីតតិយជនក្រោយពេលលុបចោលកិច្ចសន្យានោះទេ ហេតុនេះហើយ យើងអាចបកស្រាយថា វាក្យខណ្ឌ២ កថាខណ្ឌ៤ នៃមាត្រា៣៤៦ ក៏ការពារតតិយជនក្រោយពេលលុបចោលកិច្ចសន្យាផងដែរ។ ប៉ុន្តែ តាមរយៈហេតុផលដែលបានពន្យល់ខាងលើ ការការពារតតិតជនក្រោយពេលលុបចោលកិច្ចសន្យា មានទ្រឹស្តីដែលយកតាមប្រព័ន្ធការពារណដែលបានចុះកិច្ចសន្យាជាមួយជនដែលគ្មានសិទ្ធិ (ឬក៏ជនដែលមានសិទ្ធិមិនពេញលេញ)។

**ករណីសិក្សាទី៤**

Aបានគិតថានឹងលក់ដី X ទៅឲ្យ B ក្នុងតម្លៃ ១០០០០០ដុល្លា។ ហេតុនេះ A បានផ្ញើ Email ទៅឲ្យ B ប៉ុន្តែបានច្រឡំចំនួនទឹកប្រាក់ ដោយបានផ្ញើ Email ថា" ខ្ញុំចង់លក់ដី X ក្នុងតម្លៃ ១០០០០ដុល្លារ តើចង់ទិញដែរឬទេ ?"។ B បានដឹងថា A ច្រឡំចំនួនទឹកប្រាក់ដែរ ប៉ុន្តែ B នៅតែផ្ញើ Email ទៅ A ដោយសរសេរថា "ទិញ" ហើយក៏បានបង្កើតកិច្ចសន្យាលក់ទិញរវាង A និង B។ នៅថ្ងៃនោះB បានធ្វើសំណើទៅ C ដែលជាអ្នកស្គាល់គ្នាថាចង់លក់ដី X ក្នុងតម្លៃ ៧០០០០ដុល្លារ។ C គិតថាជាតម្លៃថោក ក៏បានសាកសួរទៅ B ហើយ B បានសារភាពថា ខ្លួនអាចទិញដី X ក្នុងតម្លៃ ១០០០០ដុល្លារ ដោយសារ A បានច្រឡំអំពីចំនួនទឹកប្រាក់។ A បានលុបចោលកិច្ចសន្យា

[45] មាត្រា៣៥៨ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ជាមួយ B ដោយមូលហេតុនៃការភាន់ច្រឡំនេះ។ តើ A អាចអះអាងអំពីការលុបចោលដោយមូលហេតុនៃការភាន់ច្រឡំចំពោះ C បានដែរឬទេ? A អាចអះអាងអំពីការលុបចោលដោយមូលហេតុនៃការភាន់ច្រឡំចំពោះ C បាន។[46]

**ករណីសិក្សាទី៥**

ស្រដៀងគ្នានឹងករណីសិក្សាទី៤ដែរ ប៉ុន្តែមានចំណុចខុសគ្នាបន្តិច។ ដោយសារ A បានច្រឡំចំនួនទឹកប្រាក់ A ក៏អះអាងពីការភាន់ច្រឡំ ហើយបានលុបចោលកិច្ចសន្យាលក់ទិញដី X ជាមួយ B។ ប៉ុន្តែ ការចុះបញ្ជីកម្មសិទ្ធិលើដី X គឺ A បានផ្ទេរទៅឲB រួចហើយ ហើយពុំទាន់បានផ្ទេរត្រលប់ទៅ A វិញទេ។ ហេតុនេះ B បាននិយាយអំពីហេតុការណ៍ទាំងអស់ប្រាប់ C ហើយលក់ដី X និងបានចុះបញ្ជីផ្ទេរកម្មសិទ្ធិទៅឲ C។ តើA អាចទាមទារ C ឲ្យប្រគល់ដី និងផ្ទេរការចុះបញ្ជីដី X មកឲ្យខ្លួនវិញ បានដែរឬទេ? ភាពខុសគ្នារវាងករណី សិក្សាទី៤ គឺ តើកិច្ចសន្យាលក់ទិញរវាង B និង C ធ្វើឡើងនៅមុខ ឬ ក្រោយពេល A បានលុបចោលកិច្ចសន្យាដោយមូលហេតុការភាន់ច្រឡំ។ បើកិច្ចសន្យាលក់ទិញរវាងB និង C ធ្វើឡើងនៅពេល A បានលុបចោលកិច្ចសន្យាដោយមូលហេតុការភាន់ច្រឡំ នោះA មិនអាចទាមទារ C ឲ្យប្រគល់ដី និងផ្ទេរការចុះបញ្ជីដី Xមកឲ្យខ្លួនវិញទេ។ ប៉ុន្តែបើកិច្ចសន្យាលក់ទិញរវាងB និង C ធ្វើឡើងនៅក្រោយពេលA បានលុបចោលកិច្ចសន្យាដោយមូលហេតុការភាន់ច្រឡំជាមួយ B នោះ A អាចទាមទារ Cឲប្រគល់ដី និងផ្ទេរការចុះបញ្ជីដីX មកឲ្យខ្លួនវិញបាន។[47]

### ៣.៣.២ ការឆបោក

**និយមន័យ**

ការឆបោក គឺជាស្ថានភាពដែលភាគីម្ខាងទៀតយល់ច្រឡំទៅលើអង្គហេតុ និងបង្ហាញឆន្ទៈដោយសារសកម្មភាពបំភ្លៃអង្គហេតុ ឬជាសកម្មភាពលាក់បាំងអង្គហេតុពិត។[48]

បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។ ឧទាហរណ៍ បុគ្គលិករបស់ហាងលក់សំលៀកបំពាក់អមាបានបញ្ចុះបញ្ចូលអតិថជនឲជឿលើអង្គហេតុថា សំលៀកបំពាក់នោះផលិតដោយក្រុមហ៊ុនសំលៀកបំពាក់ប្រទេសបារាំង ដែលជាសម្លៀកបំពាក់ពេញនិយម ទាំងដឹងថាការពិតសំលៀកបំណាក់នោះគឺជាផលិតផលរបស់ក្រុមហ៊ុនប្រទេសចិន ហើយអតិថិជនក៏ជឿ និងបានទិញសំលៀកបំពាក់នោះ។ អតិថិជនអាចលុបចោលកិច្ចសន្យាដោយផ្អែកលើការឆបោកបាន។

#### ៣.៣.២.១ ការលុបចោលដោយការឆបោក

-មានល័ក្ខខ័ណ្ឌជាមួយបុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀតអាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[49]

[46] មាត្រា៣៤៦ កថាខណ្ឌទី៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និងមាត្រា ៩៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

[47] មាត្រា៣៤៦ កថាខណ្ឌទី៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និងមាត្រា ៩៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

[48] មាត្រា៣៤៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ល័ក្ខខ័ណ្ឌនៃការឆបោក**

**ក) សកម្មភាពបោកបញ្ឆោត ឬ បំភ្លៃការពិត**

-សកម្មភាពប្រាប់អង្គហេតុមិនពិត ឬសកម្មភាពលាក់អង្គហេតុ ឬបំភ្លៃអង្គហេតុ។ ប៉ុន្តែចាំបាច់ត្រូវស្ថិតនៅក្នុងកម្រិតដែលមិនត្រូវបានអនុញ្ញាតដោយសង្គម។

-ក្នុងករណីតតិយជនក្រៅពីភាគីនៃកិច្ចសន្យាជាអ្នកធ្វើសកម្មភាពឆបោក អ្នកបង្ហាញឆន្ទៈ អាចលុបចោលកិច្ចសន្យាបាន ដោយផ្អែកលើភាគីម្ខាងទៀតនៃកិច្ចសន្យាបានដឹង ឬ អាចដឹងអំពីការឆបោកនោះ។[50]

**ឧទាហរណ៍ (សកម្មភាពអង្គហេតុមិនពិត)៖** នៅពេលលក់ដីមួយកន្លែង គាត់លក់ក្នុងតម្លៃថ្លៃ ដោយប្រាប់អង្គហេតុមិនពិតថា នឹងមានគម្រោងឯកសាងផ្លូវហៃវេមួយជាប់នឹងដីនេះនៅឆ្នាំក្រោយ។

**ឧទាហរណ៍ (សកម្មភាពលាក់អង្គហេតុ)៖** នៅពេលលក់ដី គាតលក់ក្នុងតម្លៃថ្លៃ ដោយមិនបានប្រាប់ពីរឿងហេតុ ដែលដីនោះមានជាប់ហ៊ីប៉ូតែក។

-មិនចាត់ទុកជាការឆបោកទេ ចំពោះកម្រិតនៃការកុហកដែលស្ថិតក្នុងទំហំនៃបច្ចេកទេសក្នុងការចចារទាក់ទងនឹង កិច្ចការពាណិជ្ជកម្ម ឬកិច្ចការផ្សេងទៀត។

**ឧទាហរណ៍ទី១៖** អ្នកលក់សំលៀកបំពាក់បានប្រាប់អ្នកទិញថា សំលៀកបំពាក់នេះអ្នកស្លៀកពាក់ទៅគឺសមហើយ។ អ្នកទិញក៏សម្រេចចិត្តទិញសំលៀកបំពាក់នោះ។ តាមពិតសម្លៀកបំពាក់នោះ អ្នកទិញស្លៀកមិនសមទេ។

**ឧទាហរណ៍ទី២៖** អ្នកលក់ឡានបានប្រាប់អ្នកទិញថា ឡានពណ៌ទឹកមាសពេញនិយមណាស់នាពេលបច្ចុប្បន្ន។ អ្នកទិញក៏បានទិញឡានពណ៌ទឹកមាសនោះ។ តាមពិតឡានពណ៌ទឹកមាសនោះមិនសូវពេញនិយមទេ។

**ខ) ចេតនានៃការឆបោក**

ដើម្បីឲការឆបោកកើតមានឡើង លុះត្រាតែអ្នកឆបោកដឹងថា អង្គហេតុដែលខ្លួននិយាយនោះជាអង្គហេតុមិនពិត។ ប៉ុន្តែ ករណីអ្នកដែលបានប្រាប់អង្គហេតុមិនពិតមិនបានដឹងអំពីភាពមិនពិតនោះទេ អ្នកប្រាប់អង្គហេតុនោះមិនមានចេតនាក្នុងការឆបោកនោះទេ។ ហេតុនេះការឆបោកក៏មិនកើតឡើងដែរ។

ឧទាហរណ៍ ករណីលក់នាឡិកាម៉ាកល្បីក្លែងក្លាយ ក្នុងតម្លៃខ្ពស់ដោយអ្នកលក់ជឿថារបស់ពិត ននោះអ្នកលក់ មិនមានចេតនាឆបោកទេ ហេតុនេះការឆបោកក៏មិនកើតឡើងដែរ។ ករណីនេះអាចជាការបង្ហាញពត៌មានមិនពិត[51] ឬជាការភាន់ច្រឡំរួម។[52]

---

[49] មាត្រា៣៤៧ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[50] មាត្រា៣៤៧ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[51] មាត្រា៣៤៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[52] មាត្រា៣៤៦ កថាខណ្ឌទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អ្នកបង្ហាញឆន្ទៈជឿជាក់ថាសកម្មភាពកុហិនោះ ជាអង្គហេតុពិត។ ឧទាហរណ៍ ករណីអ្នកលក់ទំនិញក្លែងក្លាយនៅក្នុងផ្សារដែលមានលក់ទាំងទំនិញក្លែងក្លាយ និងទំនិញពិតប្រាកដ បាននិយាយទៅកាន់អ្នកទិញថា ទំនិញនេះជាទំនិញពិតប្រាកដ តែលក់ក្នុងតម្លៃ៥០ដុល្លារ ដែលតម្លៃទំនិញពិតប្រាកដគឺ១០០ដុល្លារ ហើយតម្លៃទំនិញក្លែងក្លាយគឺ២០ដុល្លារ។ អ្នកទិញជឿថា ទំនិញនេះជាទំនិញពិត។ ករណីនេះជាការឆបោក។

**ករណីសិក្សាទី៦**

B បានគិតថាចង់បានដី X ដែលជាកម្មសិទ្ធិរបស់ A។ ប៉ុន្តែ A ហាក់មិនចង់លក់ដី X នេះទេ។ ហេតុនេះ B បាននិយាយបោកប្រាស់ A ថា «ដី X កាលពីមុនបានសាងសង់រោងចក្រផលិតឱសថ ហើយបច្ចុប្បន្នក៏នៅមានសារធាតុពុលចេញពីដីដែរ»។ A បានជឿសម្តីរបស់B ហើយក៏លក់ដី X ឲ្យទៅ B។ ថ្ងៃបន្ទាប់ A បានដឹងពីការបោកប្រាស់របស់ B តើA អាចលុបចោលកិច្ចសន្យាលក់ទិញដោយមូលហេតុនៃការឆបោកបានដែរឬទេ?

A អាចលុបចោលកិច្ចសន្យាលក់ទិញដោយមូលហេតុនៃការឆបោកបាន។[53]

**៣.៣.២.២ ការឆបោកដោយតតិយជន**

មានល័ក្ខខ័ណ្ឌខ្លះដើម្បីសម្របសម្រួលនូវការការពារអ្នកបង្ហាញឆន្ទៈដែលត្រូវបានឆបោកជាមួយនឹងផលប្រយោជន៍របស់ភាគីម្ខាងទៀត។ ការអនុញ្ញាតឲ្យលុបចោលបាននូវកិច្ចសន្យា លុះត្រាតែក្នុងករណីភាគីម្ខាងទៀតបានដឹង ឬអាចដឹងអំពីការឆបោក។[54]

**ករណីសិក្សាទី៧**

ដូចករណីសិក្សាទី៦ដែរ B បានពិភាក្សាជាមួយ C ដែលជាមិត្តភក្តិថា «ខ្ញុំកំពុងតែមានបញ្ហាដោយសារ A មិនព្រមលក់ដី X ឲ្យមកខ្ញុំសោះ»។ C គិតថានឹងជួយ B ហើយបាននិយាយបោកប្រាស់ A ថា «ដី X កាលពីមុនបានកសាងរោងចក្រផលិតឧសថ ហើយបច្ចុប្បន្នក៏នៅមានសារធាតុពុលចេញពីដីដែរ»ហេតុនេះ A បានសម្រេចលក់ដីXទៅឲ្យ B ។ B មិនបានដឹងអំពីការណ៍ដែល C បោកប្រាស់ A ទេប៉ុន្តែស្រាប់តែA បានប្រាប់ថាព្រមលក់ដី X ឲ្យទៅB ភ្លាមនោះ B ក៏គិតបានថា C បានជួយអ្វីមួយជាមិនខាន។ តើ A អាចលុបចោលកិច្ចសន្យាជាមួយ B ដោយមូលហេតុនៃការឆបោកបានដែរឬទេ?

ដើម្បីពិភាក្សាទៅលើករណីសិក្សាខាងលើ យើងគប្បីពិនិត្យទៅលើល័ក្ខខ័ណ្ឌតម្រូវនៅក្នុងមាត្រា ៣៤៧ (២) ក្នុងនោះមាន៖

| | |
|---|---|
| **ល័ក្ខខ័ណ្ឌទី១៖** | ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជន។ |
| **ល័ក្ខខ័ណ្ឌទី២៖** | ១. ករណីភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈបានដឹង ឬ |

[53] មាត្រា៣៤៧ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[54] មាត្រា៣៤៧ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

២. អាចដឹងអំពីការឆបោក

ដូចនេះក្នុងករណីនេះ យើងត្រូវបញ្ជាក់ថាតើ A អាចដឹងអំពីការឆបោករបស់C បានដែរឬទេ។[55] យើងឃើញថា A បានសម្រេចចិត្ត លក់ដី គឺដោយសារការឆបោករបស់C មានន័យថា A បានដឹងអំពីការឆបោករបស់C ។ ល័ក្ខខ័ណ្ឌទី១ ត្រូវបានបំពេញ។ បន្ទាប់មកយើងត្រូវពិនិត្យមើលល័ក្ខខ័ណ្ឌទី២ បន្តទៀត។ តើ B បានដឹងពីការឆបោករបស់C ដែរឬទេ? តាមអង្គហេតុ B មិនបានដឹងអំពីការឆបោករបស់ C ទេ។ ដូច្នេះ ល័ក្ខខ័ណ្ឌទី២ ចំណុចទី១ មិនបានបំពេញទេ។ យើងត្រូវពិនិត្យមើលចំណុចទី២ ទៀត ថាតើ B អាចដឹងអំពីការឆបោករបស់C ដែរឬទេ? តាមអង្គហេតុ B បានគិតថា « C បានជួយអ្វីម៉្យាងជាមិនខាន »។ មានន័យថា B អាចនឹងដឹងអំពីការឆបោករបស់ C។ ដូច្នេះល័ក្ខខ័ណ្ឌទី២ ចំណុច២ត្រូវបានបំពេញ។ សរុបសេចក្តីមក A អាចលុបចោលកិច្ចសន្យាជាមួយ B ដោយមូលហេតុនៃការឆបោកបាន។

**៣.៣.២.៣ ការឆបោក និង តតិយជន**

ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជន បាន។ ប៉ុន្តែ ប្រសិនបើតតិជនជាជនសុចរិតហើយគ្មានកំហុសអំពីការឆបោកមិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ។[56]

**ករណីសិក្សាទី៨**

ដូចគ្នានឹងករណីសិក្សាទី៦ បន្ទាប់ពី B បានបោកប្រាស់ A ហើយបានទិញដី X ពីA ហើយB ក៏បានលក់ដី X នោះទៅឲ្យ C។ C មិនបានដឹងអំពីការណ៍ដែល B បោកប្រាស់ A ទេ ហើយក៏មិនមានកំហុសក្នុងការមិនដឹងនេះដែរ។ ក្រោយមក A បានលុបចោលនូវកិច្ចសន្យាជាមួយ Bដោយមូលហេតុនៃការឆបោក។ តើ A អាចអះអាងពីការលុបចោលដោយការឆបោកចំពោះ C បានដែរឬទេ?

ដំបូងយើងត្រូវពិនិត្យមើលល័ក្ខខ័ណ្ឌនៃការឆបោកយើងដូចខាងក្រោមៈ[57]

-តតិយជនជាជនទុច្ចរិត ឬ

-តតិយជនមានកំហុសអំពីការឆបោក

តាមអង្គហេតុខាងលើ យើងឃើញថា C ជាជនសុចរិត ដូច្នេះ ល័ក្ខខ័ណ្ឌទី១ មិនត្រូវបានបំពេញទេ។ យើងត្រូវពិនិត្យមើលល័ក្ខខ័ណ្ឌទី២ទៀត។ តាមអង្គហេតុដដែល C ជាជនគ្មានកំហុសអំពីការឆបោកនេះទេ ដូច្នេះល័ក្ខខ័ណ្ឌទី២ក៏មិនត្រូវបានបំពេញទៀត។ សរុបមក យើងអាចសន្និដ្ឋានបានថា A មិនអាចអះអាងអំពីការលុបចោលកិច្ចសន្យាជាមួយ C បានទេ។

**ករណីសិក្សាទី ៩**

[55] មាត្រា៧៥ ក្រមនីតិវីធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[56] មាត្រា៣៤៧ កថាខណ្ឌទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ដូចគ្នានឹងករណីសិក្សាទី ៦ A បានលុបចោលកិច្ចសន្យាជាមួយ B ដោយមូលហេតុនៃការ ឆបោក។ ប៉ុន្តែការចុះបញ្ជីកម្មសិទ្ធិលើដី បានផ្ទេរពី A ទៅឲ B ហើយមិនទាន់បានផ្ទេរត្រលប់ទៅឲ្យ A វិញទេ។ B ប្រើប្រាស់ការចុះបញ្ជីដីនោះជារបស់ខ្លួន ហើយក៏លក់ដី X ទៅឲ្យ C និងបានផ្ទេរការចុះបញ្ជីទៅឲ្យ C។ C បានដឹងអំពីការណ៍ដែល B បានបោកប្រាស់ A។ តើ A អាចអះអាងពីការលុបចោលដោយការឆបោក ហើយទាមទារ C ឲ្យប្រគល់ដី X និងផ្ទេរការចុះបញ្ជីត្រឡប់មកខ្លួនវិញ បានដែរឬទេ? A អាចអះអាងពីការលុបចោលដោយការឆបោក ហើយទាមទារ C ឲ្យប្រគល់ដី X និងផ្ទេរការចុះបញ្ជីត្រឡប់មកខ្លួនវិញបាន ព្រោះ C បានដឹងអំពីការណ៍ដែល B បានបោកប្រាស់ A (មាត្រា៣៤៧ កថាខណ្ឌទី៣ អនុញ្ញាតឲ្យលុបចោលកិច្ចសន្យាលុះត្រាតែក្នុងករណី ភាគីម្ខាងទៀតបានដឹង ឬអាចដឹងអំពីការឆបោក) ។

- A អាចអះអាងពីការលុបចោលដោយការឆបោក ហើយទាមទារ C ឲ្យប្រគល់ដី X និងផ្ទេរការចុះបញ្ជីត្រឡប់មកខ្លួនវិញបាន ព្រោះ C បានដឹងអំពីការណ៍ដែរ B បានបោកប្រាស់ A (មាត្រា៣៤៧ កថាខណ្ឌទី៣ អនុញ្ញាតឲ្យលុបចោលកិច្ចសន្យា) ។ ប្រើបានទាំងតតិយជនក្រោយ និងមុនពេលលុបចោលកិច្ចសន្យាបាន។
- ប្រសិនបើ មាត្រា ១៣៤ និងមាត្រា ១៣៥[58] ដើម្បីកំណត់អ្នកឈ្នះអ្នកចាញ់ ទោះ C ជាជនសុចរិត ឬទុច្ចរិតក៏ដោយ C យល់ថា B មានការចុះបញ្ជី ដូច្នេះ C ត្រូវបានការពារ។ បើ C បានចុះបញ្ជីមុន A មិនអាចអះអាងពីការលុបចោល និងមិនអាចទាមទារឲ្យ C ផ្ទេរការចុះបញ្ជីត្រឡប់មកខ្លួនវិញបានទេ។ បើមាត្រា ៣៥៣ កថាខណ្ឌទី២[59] C បានទិញដីពីជនដែលមិនមានសិទ្ធិ B ដូច្នេះ A អាចទាមទារការចុះបញ្ជីពី C មកវិញបាន ដោយការអនុវត្តដោយប្រយោល ហើយ C ជាជនទុច្ចរិតមិនត្រូវបានការពារទេ។

### ៣.៣.៣ ពត៌មានមិនពិត

#### ៣.៣.៣.១ ការលុបចោលដោយមូលហេតុពត៌មានមិនពិត

ក្នុងការអនុវត្តនៅទីនេះការពារភាគីបង្ហាញឆន្ទៈ នេះការពារភាគីបង្ហាញ ឆន្ទៈ ដោយផ្អែកលើពត៌មានមិនពិតដែលត្រូវបាន បង្ហាញដោយភាគីម្ខាងទៀត។[60] ប្រសិនបើភាគីម្ខាងទៀតបង្ហាញពត៌មានមិនពិតដោយចេតនា សកម្មភាពនេះក្លាយជា ការឆបោក ហេតុដូច្នេះ អ្នកបង្ហាញឆន្ទៈត្រូវបានការពារដោយយោងតាម មាត្រា៣៤៧។[61] ប៉ុន្តែ ប្រសិនបើភាគីម្ខាងទៀត មិនបានធ្វើដោយចេតនាទេ ការបង្ហាញឆន្ទៈនេះមិនអាចលុបចោលដោយហេតុផលនៃការឆបោកបានទេ។ ម៉្យាងទៀត ក្នុងករណីដែលពត៌មានមិនពិតត្រូវបានបង្ហាញដោយភាគីម្ខាងទៀតមានករណី

[57] មាត្រា៣៤៧ កថាខណ្ឌទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[58] មាត្រា១៣៤ និង១៣៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[59] មាត្រា៣៥២ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[60] មាត្រា៣៤៨ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ច្រើនដែលអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំ ហេតុដូច្នេះ ការលុបចោលកិច្ចសន្យាអាចអនុញ្ញាតដោយហេតុផលនៃការភាន់ច្រឡំ។ ប៉ុន្តែការលុបចោលនូវកិច្ចសន្យាដោយសារការភាន់ច្រឡំតម្រូវថា ការភាន់ច្រឡំត្រូវទាក់ទងនឹងចំណុចសំខាន់ៗនៃកិច្ចសន្យា និងភាគីម្ខាងទៀតត្រូវមានលទ្ធភាពក្នុងការដឹងអំពីការភាន់ច្រឡំនេះ។[62]

ការរក្សាទុក មានគោលគំនិត ការពារភាគីបង្ហាញឆន្ទៈ ដោយផ្អែកលើព័ត៌មានមិនពិត ដែលត្រូវបានបង្ហាញដោយភាគីម្ខាងទៀត។[63]

**ករណីសិក្សាទី១០**

A គិតថានឹងជួលផ្ទះល្វែងនៅក្នុងទីក្រុងភ្នំពេញ ហើយបានពិភាក្សាជាមួយ B ដែលជាអ្នកប្រកបរបរអាជីវកម្ម អចលនវត្ថុ។ B បានណែនាំផ្ទះ X ឲទៅ A។ B បានពន្យល់អំពីផលប្រយោជន៍ជាច្រើនដូចជា នៅជិតផ្ទះនោះមានផ្សារដែលមានភាពងាយស្រួល មានពន្លឺព្រះអាទិត្យចេញចូលល្អ ហើយនៅលើដំបូលមានអាងហែលទឹកកន្លែងហាត់ប្រាណជាដើម។ ដោយសារ A ចូលចិត្តហែលទឹក ហេតុនេះក៏ចាប់អារម្មណ៍អាងហែលទឹកនោះយ៉ាងខ្លាំងបំផុត ហើយសម្រេច ថាជួលផ្ទះ X ដើម្បីស្នាក់នៅ។ ប៉ុន្តែ អាងហែលទឹកនោះបានខូចកាលពី១ឆ្នាំមុន ហើយមានសភាពដែលមមិនអាចប្រើប្រាស់បាន។ B មិនបានដឹងអំពីចំណុចនេះទេ។ ក្នុងករណីនេះ តើA ត្រូវបានការពារដោយរបៀបណា?

មុនដំបូងយើងត្រូវពិនិត្យនូវល័ក្ខខ័ណ្ឌចំនួន៣នៃមាត្រា ៣៤៨ កថាខណ្ឌទី១ ដូចខាងក្រោម៖

-នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត

-ភាគីដែលបង្ហាញឆន្ទៈជឿថាអង្គហេតុនោះជាការពិរ

-ប្រសិនបើភាគីដឹងថាអង្គហេតុនោះមិនមែនជាការពិត ភាគីនោះមិនបង្ហាញឆន្ទៈ [ ការបកស្រាយអង្គហេតុ]

ក្នុងករណីសិក្សាខាងលើ B បានប្រាប់ A អំពីការមានអាងហែលទឹកនៅលើដំបូលផ្ទះ។ ប៉ុន្តែ តាមពិតអាងហែលទឹកនោះមិនអាចដំណើរការបានទេ។ ដូច្នេះ ល័ក្ខខ័ណ្ឌទី១ត្រូវបានបំពេញ។ បន្ទាប់មកយើងបង្ហាញល័ក្ខខ័ណ្ឌទី២ទៀត។ ក្នុងករណីនេះ A នៅពេលបង្កើតកិច្ចសន្យា ជឿថាមានអាងហែលទឹក។ ដូច្នេះ ល័ក្ខខ័ណ្ឌទី២ ត្រូវបាន បំពេញ។ ចុងក្រោយ យើងពិនិត្យមើលល័ក្ខខ័ណ្ឌទី៣។

យើងឃើញថា ប្រសិនបើ A ដឹងថាមិនមានអាងហែល ដែលអាចដំណើរការបានខ្លួនក៏មិនបង្ហាញឆន្ទៈជួលផ្ទះនោះដែរ។ ដូច្នេះ ល័ក្ខខ័ណ្ឌទី៣ ត្រូវបានបំពេញទៀត។ សរុបមក A អាចលុបចោលកិច្ចសន្យាជួលផ្ទះនោះបាន។

[61] មាត្រា៣៤៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[62] មាត្រា៣៤៧ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[63] មាត្រា៣៤៨ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

គោលបំណង ចែងថា ប្រសិនបើភាគីដែលបង្ហាញព័ត៌មានមិនពិតមានកំហុសក្នុងការបង្ហាញព័ត៌មានមិនពិតនេះ ភាគីនោះត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាត។[64] ក្នុងករណីនេះ គួរបកស្រាយថា ភាគីដែលទទួលរងនូវការខូចខាត អាចលុបចោលកិច្ចសន្យា និងទាមទារសំណងនៃការខូចខាតដែលនៅសល់ក្រោយការលុបចោលបាន ឬក៏អាចទាមទារសំណងនៃការខូចខាតដោយមិនលុបចោលកិច្ចសន្យាបានដែរ។

#### ៣.៣.៣.២ ព័ត៌មានមិនពិត និង តតិយជន

ប្រសិនបើកិច្ចសន្យាត្រូវបានលុបចោលដោយសារហេតុផលនៃព័ត៌មានមិនពិត អានុភាពនៃការលុបចោលកិច្ចនសន្យាអាចតតាំងបាន មិនត្រឹមតែភាគីម្ខាងទៀតប៉ុណ្ណោះទេ ថែមទាំងតតិយជន ដូចជាអ្នកធ្វើលទ្ធកម្មជាបន្តបន្ទាប់ផងដែរ។[65]

### ៣.៣.៤ ការរំលោភបំពានលើស្ថានភាព

#### ៣.៣.៤.១ ការលុបចោលដោយមូលហេតុការរំលោភបំពានលើស្ថានភាព

អ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន លុះត្រាតែក្នុងករណីដែលមាន «ការប្រើដោយមិនត្រឹមត្រូវ» នូវស្ថានភាពនេះប៉ុណ្ណោះ។[66] មាត្រា ៤៥ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីហូឡង់ ឲនិយមន័យអំពីការរំលោភបំពានលើស្ថានភាពថា «ក្នុងករណីដែលភាគីម្ខាងដឹង ឬគួរដឹងថាភាគីម្ខាងទៀតត្រូវបាន នាំឲធ្វើសកម្មភាពគតិយុត្តដែលជាលទ្ធផលនៃគារស្ថានភាពពិសេស ដូចជាភាពចាំបាច់ ភាពពឹងពាក់ការធ្វើសកម្មភាព ភ្លាមៗដែលខ្វះការពិចារណា ស្ថានភាពខាងប្រាជ្ញាមិនប្រក្រតី ឬភាពខ្វះខាតបទពិសោធន៍ ហើយជម្រុញឲ្យភាគីម្ខាងទៀតធ្វើសកម្មភាពបែបនេះ ទោះបីខ្លួនមិនគួរនាំឲភាគីម្ខាងទៀតធ្វើសកម្មភាពក៏ដោយ នោះភាគីនោះប្រព្រឹត្ត សកម្មភាពរំលោភបំពានលើស្ថានភាព» មាត្រានេះនឹងមានប្រយោជន៍ក្នុងការការពារអ្នកទន់ខ្សោយផ្នែកសេដ្ឋកិច្ច ឬសង្គម ជាពិសេសអ្នកប្រើប្រាស់។

គោលគំនិតនៃមាត្រា ៣៤៩ កថាខណ្ឌទី១នេះ និងមានផលប្រយោជន៍ក្នុងការការពារអ្នកទន់ខ្សោយផ្នែកសេដ្ឋកិច្ច ឬ សង្គម។

ឧទាហរណ៍ ក្នុងករណីដែលស្ថានភាពនិយោជកបង្ខំឲនិយោជិតលក់ដីមកឲខ្លួន បើសិនជានិយោជិតមិនយល់ ព្រមលក់ដីឲខ្លួនទេ និយោជកអាចនឹងបញ្ឈប់និយោជិតនោះពីការងារ។ ដោយនិយោជិតខ្លាចបាត់បង់ការងារខ្លួន ក៏សម្រេចចិត្តលក់ដីនោះ។

---

[64] មាត្រា៣៤៨ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[65] មាត្រា៣៤៨ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[66] មាត្រា៣៤៩ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ៣.៣.៤.២ ការរំលោភបំពានលើស្ថានភាព និងតតិយជន

អានុភាពនៃការលុបចោលកិច្ចសន្យាដែលភាគីម្ខាងបានធ្វើដោយហេតុថា ភាគីម្ខាងទៀតបានប្រើឋានៈខ្លួនខាងផ្នែកសេដ្ឋកិច្ច ជាអាទិ៍ ចំពោះតតិយជន។[67] ដើមសម្របសម្រួលជាមួយនឹងផលប្រយោជន៍របស់តតិយជនដែលជាជនសុចរិតហើយគ្មានកំហុស កថាខណ្ឌនេះចែងថា ការលុបចោលកិច្ចសន្យា ដោយហេតុនៃការរំលោភលើស្ថានភាព មិនអាចតតាំងចំពោះតតិយជនសុចរិតដែលគ្មានកំហុសបានឡើយ។

### ៣.៣.៥ ការគំរាមកំហែង

**មានល័ក្ខខ័ណ្ឌ**

ក្នុងការអនុវត្ត អំពីការលុបចោលកិច្ចសន្យាដោយមូលហេតុនៃការគំរាមកំហែង។[68] ការបង្ហាញឆន្ទៈដោយការគំរាមកំហែង ក៏ជាការបង្ហាញឆន្ទៈដែលអ្នកបង្ហាញឆន្ទៈគ្មានបំណងបង្ហាញដែរហេតុដូច្នេះ មាត្រានេះការពារអ្នកបង្ហាញឆន្ទៈដោយអនុញ្ញាតឲអ្នកបង្ហាញឆន្ទៈលុបចោលកិច្ចសន្យា។ ខុសគ្នានឹងករណីនៃការឆបោកក្នុងករណីនៃការគំរាមកំហែងដែលធ្វើដោយតតិយជន ក្រមនេះបានអនុម័តយកជំហរ ដែលកិច្ចសន្យាអាចលុបចោលបានទោះបីជាភាគីម្ខាងទៀតគ្មានលទ្ធភាពដឹងអំពីការគំរាមកំហែងក៏ដោយ។

ការឆបោក និងការគំរាមកំហែង មានចំណុចដូចគ្នាត្រង់ថា នាំឲអ្នកបង្ហាញឆន្ទៈបង្ហាញខុសឆន្ទៈពិតរបស់ខ្លួន និងនាំឲ្យមានវិការៈ។

ករណីនៃការឆបោក មានបញ្ញាត្តិស្តីពីការឆបោកដោយតតិយជន[69] និងបញ្ញត្តិស្តីពីការ ការពារ តតិយជន[70] ជាដើម ប៉ុន្តែ នៅក្នុងការគំរាមកំហែងពុំមានបញ្ញត្តិដែលកម្រិតការ តតាំងចំពោះអានុភាពនៃការលុបចោលចំពោះតតិយជនដែលជាជនសុចរិតហើយគ្មានកំហុសទេ។ ហេតុនេះហើយ ផ្អែកតាមគោលការណ៍ទូទៅ អានុភាពនៃការលុបចោលកិច្ចសន្យា ដោយសារការគំរាមកំហែង អាចតតាំងចំពោះតតិយជន ដូចជាអ្នកធ្វើលទ្ធកម្មជាបន្តបន្ទាប់បាន។ ការកំណត់បែបនេះ មានគោលបំណងឲជនរងគ្រោះនៃការគំរាមកំហែង ទទួលបាននូវការការពារធំជាងជនរងគ្រោះនៃការឆបោកជាអាទិ៍។

**ករណីសិក្សាទី១១**

B ចង់ទិញដី X ដែលជាកម្មសិទ្ធិរបស់ A ហើយB ក៏បានដាក់សំណើទៅ A ប៉ុន្តែ ត្រូវបាន A បដិសេធ។ B បានពិក្សាជាមួយ C ដែលជាមិត្តភក្តិ។ C បានដឹងថា A កំពុងតែផិតក្បត់ជាមួយស្រីផ្សេងដែលមិនមែនជាប្រពន្ធ។ ហេតុនេះ C គិតថានឹងជួយ B បាននិយាយគំរាមទៅ A ថា «ប្រសិនបើមិនលក់ដី X ឲ្យទៅB ទេ ខ្ញុំនឹងនិយាយអំពីការផិតក្បត់របស់អ្នកប្រាប់ប្រពន្ធរបស់អ្នក» ។ ហេតុនេះ A គ្មានវិធីផ្សេង ក៏បានលក់ដី X ឲទៅ B ។

---

[67] មាត្រា៣៤៩ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[68] មាត្រា៣៥០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[69] មាត្រា៣៤៧ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[70] មាត្រា៣៤៧ កថាខណ្ឌទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ក្រោយមក B បានលក់ដី X ឲ្យទៅ D។ ក្នុងករណីនេះ តើ A អាចលុបចោលកិច្ចសន្យាលក់ទិញដោយមូលហេតុនៃការគំរាមកំហែង ហើយអះអាងចំពោះ D និងឲ D ប្រគល់ដី X ត្រលប់មកវិញបានដែរឬទេ? A អាចលុបចោលកិច្ចសន្យាលក់ទិញដោយមូលហេតុនៃការគំរាមកំហែង ហើយអះអាងចំពោះ D និងឲ្យ D ប្រគល់ដី X ត្រលប់មកវិញបាន។

### ៣.៣.៦. ការកេងយកចំណេញហួសហេតុ

ចំពោះការកេងចំណេញហួសហេតុ ចំពោះករណីដែលភាគីម្ខាងទៀតជាអនីតិជនជាអាទិ៍តែប៉ុណ្ណោះ។[71]

គោលគំនិតនៃមាត្រា ៣៥១ គឺថា មានតែភាគីដែលទទួលខូចខាតផលប្រយោជន៍ប៉ុណ្ណោះ ដែលអាចលុបចោលកិច្ចសន្យាបាន។

ករណីខ្លះទៀត ដែលត្រូវយកមាត្រា ៣៥១ មកអនុវត្ត គឺករណីដែលភាគីនៃកិច្ចសន្យាជាអាជីវករ ហើយភាគីម្ខាងទៀតគឺជាអ្នកប្រើប្រាស់ ប្រសិនបើអាជីវករបានចំណេញហួសហេតុ ដោយឆ្លៀតឱកាសនៃភាពល្ងង់ខ្លៅ ឬខ្វះបទពិសោធន៍របស់អ្នកប្រើប្រាស់ អ្នកប្រើប្រាស់នោះអាចលុបចោលកិច្ចសន្យាបានដោយយោងតាមមាត្រានេះ។

### ៣.៣.៧ ឋបនីយផ្លូវចិត្ត

#### ៣.៣.៧.១ ករណីភាគីម្ខាងទៀតសុចរិត

ឋបនីយផ្លូវចិត្ត គឺជាការបង្ហាញឆន្ទៈដែលធ្វើការដោយដឹងថា ការបង្ហាញឆន្ទៈនោះមិនពិតទេ។[72] ឧទាហរណ៍ A បង្ហាញឆន្ទៈ «ធ្វើប្រទានកម្មឲទៅ B» ទោះបីជា A គ្មាបំណងធ្វើបែបនេះក៏ដោយ។ ការបង្ហាញឆន្ទៈដែលមិនពិត គឺជាការបង្ហាញឆន្ទៈដែលមានវិការៈហើយតាមគោលការណ៍នៃកិច្ចសន្យាដែលមានការបង្ហាញឆន្ទៈដែលមានវិការៈអាចលុបចោលបាន។ A ហាក់ដូចជាត្រូវបានអនុញ្ញាតឲលុបចោលកិច្ចសន្យាប្រទានកម្ម ប៉ុន្តែ ការអនុញ្ញាតឲលុបចោលក្នុងករណីនេះ ធ្វើឲខូចប្រយោជន៍របស់ B យ៉ាងខ្លាំង ប្រសិនបើ B មិនដឹងថា ការបង្ហាញឆន្ទៈរបស់ A មិនពិតទេនោះ។ ដោយដឹងថាការបង្ហាញឆន្ទៈនោះមិនពិត វាមិនចាំបាច់ការពារអ្នកបង្ហាញឆន្ទៈ A ដែលបានធ្វើឋបនីយផ្លូវចិត្តទេ។ ហេតុដូច្នេះ មាត្រានេះចែងថា កិច្ចសន្យាដែលត្រូវបង្កើតឡើងដោយឋបនីយផ្លូវចិត្តមានសុពលភាព។ តែប្រសិនបើភាគីម្ខាងទៀតដឹងអំពី ឋបនីយផ្លូវចិត្តរបស់អ្នកបង្ហាញឆន្ទៈ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន។ ករណីនេះមិនមែនមានន័យថា ការបដិសេធនូវអានុភាពនៃកិច្ចសន្យាទេ។ ហេតុដូច្នេះហើយ ទោះបីជាភាគីម្ខាងទៀត B មិនអាចទាមទារការអនុវត្តកិច្ចសន្យាចំពោះ A ក៏ដោយអ្នកធ្វើលទ្ធកម្មបន្ត C អាចធ្វើលទ្ធកម្មនូវកម្មសិទ្ធិរបស់ B ដោយមានសុភពភាពបាន ហើយ A មិនអាចអះអាងអ្វីចំពោះ C បានទេ។

---

[71] មាត្រា៣៥១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[72] មាត្រា៣៥២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

A ជាសង្សាររបស់ B ប៉ុន្តែក្រោយមក A បានស្រឡាញ់ C ហើយក៏ទៅនិយាយសុំបែកគ្នាជាមួយ B។ ប៉ុន្តែ B មិនព្រមបែកគ្នាឡើយ។ A បាននិយាយលេងសើចថា «ប្រសិនបើព្រមបែកគ្នា ខ្ញុំឲ្យលុយ ១០០០ដុល្លារ » ។ B បានឮបែបនេះហើយ បានជឿថា A និយាយមែន ក៏សម្រេចបែកគ្នាជាមួយ A។ តើ B អាចទាមទារឲ A បង់ប្រាក់ ១០០០ដុល្លារ បានដែរឬទេ? B អាចទាមទារឲ្យ A បង់ប្រាក់ ១០០០ដុល្លារ បានព្រោះ B មិនដឹងថា ការបង្ហាញឆន្ទៈរបស់A មិនពិតនោះទេ។

### ៣.៣.៧.២ ករណីភាគីម្ខាងទៀតទុច្ចរិត

កិច្ចសន្យាដែលត្រូវបានផ្តើតឡើងដោយឋបនីយផ្លូវចិត្តមានសុពលភាព។ តែប្រសិនបើភាគីម្ខាងទៀតដឹងអំពីឋបនីយផ្លូវចិត្តរបស់អ្នកបង្ហាញឆន្ទៈ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យា បាន។[73]

គោលគំនិតនៃមាត្រា ៣៥២ វាក្យខណ្ឌទី២ គឺការពារឋបនីយផ្លូវចិត្តរបស់អ្នកបង្ហាញឆន្ទៈ ក្នុងករណីដែលភាគីម្ខាងទៀតមានបំណងទុច្ចរិត។

**ករណីសិក្សាទី១៣**

ដូចនឹងករណីសិក្សាទី១២ A បាននិយាយលេងជាមួយ B ថា «ប្រសិនបើព្រមបែកគ្នា ខ្ញុំឲលុយ១០០លានដុល្លារ» ។ B បានដឹងថា Aមិនមានលុយច្រើនបែបនេះទេ ហេតុនេះ B ដឹងថា A កំពុងនិយាយលេងសើច។ ក្រោយមក A និង B បានបែកគ្នា ហើយបានកន្លងផុតរយៈពេល១ឆ្នាំ។ ដោយសារ B ត្រូវបានក្រុមហ៊ុនបណ្តេញចេញ ធ្វើឲមានបញ្ហាជីវភាព ក៏ស្រាប់តែទាមទារលុយ ១០០លានដុល្លារពី A។ តើ A អាចបដិសេធបានដែរឬទេ? A អាចបដិសេធបាន ព្រោះកិច្ចសន្យានោះមិនមានអានុភាពទៀតទេ នេះជាទុច្ចរិតភាពរបស់ B ព្រោះ B ដឹងថា A បាននិយាយលេងសើចតែប៉ុណ្ណោះ ហើយខ្លួនបានសុខចិត្តបែកគ្នាពី A បានកន្លងផុតរយៈពេល១ឆ្នាំថែម ទៀត។

### ៣.៣.៧.៣ ឋបនីយផ្លូវចិត្ត និង តតិយជន

**ករណីសិក្សាទី១៤**

A ជាសង្សាររបស់ B ប៉ុន្តែក្រោយមក A បានស្រឡាញ់ Cហើយក៏ទៅនិយាយសុំបែកគ្នាជាមួយ B។ ប៉ុន្តែ B មិនព្រមបែកគ្នាឡើយ។ A បាននិយាយលេងសើចថា «ប្រសិនបើព្រមបែកគ្នា ខ្ញុំឲ្យឡាន Luxus នេះ» ។ B បានឮបែបនេះ ដឹងថា A កំពុងនិយាយលេងសើច ហើយគិតថាចង់ធ្វើឲ្យ A មានបញ្ហា ក៏បានបើកឡាន Luxus តាមអំពើចិត្ត និងលក់ទៅឲ្យ D ដែលជាមិត្តភក្តិ ក្នុងតម្លៃ ១០០០០ដុល្លារ។ ប្រសិនបើ A ទាមទារ D ឲ្យប្រគល់ឡាន Luxus តើ D អាចបដិសេធបានដែរឬទេ? ប្រសិនបើ A ទាមទារ D ឲ្យប្រគល់ឡាន Luxus D អាចបដិសេធបាន។

[73] មាត្រា៣៥២ វាក្យខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ៣.៣.៨ អលទ្ធភាពតាំងពីដំបូង

#### ៣.៣.៨.១ អលទ្ធភាពតាំងពីដំបូង

តើករណីណាខ្លះ ដែលអត្ថន័យនៃកិច្ចសន្យា មិនអាចសម្រេចបានតាំងពីពេលដែលបង្កើតកិច្ចសន្យា? មាត្រានេះចែងថា កិច្ចសន្យាមិនត្រូវចាត់ទុកជាមោឃៈទេ ដោយហេតុផលមួយដែលហៅថា «អលទ្ធភាពតាំងពីដំបូង» អលទ្ធភាពតាំងពីដំបូងមានន័យថា នៅពេលកិច្ចសន្យាត្រូវបានបង្កើតមានភាព ច្បាស់លាស់ជាស្ថាពរថា ការអនុវត្តកិច្ចសន្យានេះមិនអាចធ្វើបានទេ។[74] សព្វថ្ងៃនេះ ប្រទេសជាច្រើនមានទិន្នាការដែលមិនបានយកអលទ្ធភាពតាំងពីដំបូងធ្វើជាមូលហេតុនៃមោឃភាពទេ កិច្ចសន្យាត្រូវបង្កើតឡើងដោយមានសុភពលភាព ទោះពីជាមានអលទ្ធភាពតាំងពីដំបូងក៏ដោយ។ ក្នុងករណីនេះ អលទ្ធភាពតាំងពីដំបូងត្រូវបានដោះស្រាយជាបញ្ហាអលទ្ធទូទៅនៃការអនុវត្ត។ ហេតុដូច្នេះហើយបញ្ហានេះត្រូវបានដោះស្រាយតាមការរំលាយកិច្ចសន្យាដោយយកអលទ្ធភាពក្នុងការអនុវត្តមកធ្វើជាមូលហេតុ ឬតាមសំណងការខូច ខាត។ ប្រសិនបើភាគីដែលធ្វើកិច្ចសន្យាដោយជឿជាក់ថា ខ្លឹមសារនៃកិច្ចសន្យាអាចអនុវត្តបាន បំពេញលក្ខខ័ណ្ឌនៃការភាន់ច្រឡំ នោះភាគីអាចលុបចោលកិច្ចសន្យា ដោយហេតុ មានការភាន់ច្រឡំ។ ឧទាហរណ៍ ក្នុងករណី A និង B បានបង្កើតកិច្ចសន្យាដូរ «រូបភាពរបស់វិចិត្រករ X» របស់ A ជាមួយនឹង «រូបចម្លាក់សេះរបស់ជាងចម្លាក់ Y» របស់ B ប្រសិនបើ «រូបចម្លាក់សេះរបស់ជាងចម្លាក់ Y» របស់ B គឺជារូបចម្លាក់ក្លែងក្លាយ ហើយជាងចម្លាក់ Y មិនដែលឆ្លាក់រូបចម្លាក់សេះទេ ការប្រគល់ «រូបចម្លាក់សេះរបស់ជាងចម្លាក់ Y» ពី B ទៅ A គឺជាអលទ្ធភាពតាំងពីដំបូង។ ប្រសិនបើ A បានធ្វើកិច្ចសន្យាដូរនេះដោយជឿជាក់ថា ពិតជាមាន «រូបចម្លាក់សេះរបស់ជាងចម្លាក់ Y» នោះ A មានការភាន់ច្រឡំ ហើយប្រសិនបើ A បានបំពេញលក្ខខ័ណ្ឌសម្រាប់ការលុបចោលកិច្ចសន្យាដោយសារភាន់ច្រឡំ A អាចលុបចោលកិច្ចសន្យាដូរនោះបាន។

#### ៣.៣.៨.២ ការទទួលខុសត្រូវក្នុងការសងការខូចខាត

តើករណីណាខ្លះដែលអាចទាមទារសំណងការខូចខាតបាន?

បន្ថែមពីការទទួលខុសត្រូវទូទៅក្នុងការសងសំណងការខូចខាត ដោយសារការមិនអនុវត្តកាតព្វកិច្ចដូចដែលបានរៀបរាប់ខាងលើ ភាគីដែលបានដឹងអំពីអលទ្ធភាពតាំងពីដំបូងនៅពេលធ្វើកិច្ចសន្យា ត្រូវទទួលខុសត្រូវការសងសំណងការខូចខាត ទៅភាគីម្ខាងទៀតដែលបានធ្វើកិច្ចសន្យាគ្មានប្រយោជន៍នេះ។[75] នេះគឺជាបញ្ហានៃកំហុសក្នុងការបង្កើតកិច្ចសន្យា។

កថាខណ្ឌទី២ ចែងអំពីបញ្ហានេះ។ ការទទួលខុងត្រូវដែលមានចែងក្នុងកថាខណ្ឌទី២នោះ ខុសពីការទទួលខុសត្រូវចំពោះការបង្កើតមូលហេតុនៃអលទ្ធភាព។ ឧទាហរណ៍ ចំពោះកិច្ចសន្យាលក់ផ្ទះនៅស្រុកស្រែមួយរបស់ A ទៅឲ្យ B ប្រសិនបើផ្ទះនៅស្រុកស្រែនោះ ត្រូវបានឆេះ ដោយសារការដុតរបស់តតិយជននៅមុនថ្ងៃចុះកិច្ច

[74] មាត្រា៣៥៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[75] មាត្រា៣៥៥ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

សន្យា អ្នកលក់ A មិនចាំបាច់ទទួលខុសត្រូវពីអលទ្ធភាពក្នុងការអនុវត្តប៉ុន្តែ A គួរបានដឹងអំពីការចេះ ដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញមុនកាលបរិច្ឆេទចុះកិច្ចសន្យា ដោយទទួលបានពត៌មានអំពីផ្ទះនោះ។ ប្រសិនបើ A បានដឹងហើយបានជូនដំណឹងទៅភាគីម្ខាងទៀត A អាចជៀសវាងមិនឲភាគីម្ខាងទៀតធ្វើកិច្ចសន្យាដែលគ្មានប្រយោជន៍នេះបាន។ កថាខណ្ឌទី២ ចែងអំពីការទទួលខុសត្រូវក្នុងការសងសំណងការខូចខាតទៅឲភាគីម្ខាងទៀត B ក្នុងករណីបែបនេះ។

**មូលហេតុដែលនាំឲ្យមានឆន្ទៈខាងក្នុង**

(ក) ចង់ទិញដី (ខ) ដោយយល់ថា ទៅថ្ងៃមុខនឹងមានសាងសង់ផ្សារទំនើបនៅជិតទីនោះ។ ពេលនោះ (ក) បានសុំទិញដីនោះពី (ខ) ក្នុងតម្លៃ ១០០០០០ដុល្លាអាមេរិក ភាគី (ខ) ក៏យល់ព្រម ក៏ឈានដល់ការកក់លុយ ដើម្បីបង្កើតកិច្ចសន្យាលក់ទិញមួយនៅថ្ងៃបន្ទាប់។ ប៉ុន្តែនៅថ្ងៃបន្ទាប់ភាគី (ក) បានដឹងថាមិនមានការសាងសង់ផ្សារទំនើបអ្វីទេនៅជិតដីនោះ ទៅថ្ងៃខាងមុខ ដូច្នេះហើយភាគី (ក) មិនព្រមធ្វើកិច្ចសន្យាកក់លុយ ដើម្បីទិញដីនោះជាមួយភាគី (ខ)ឡើយ។ តើភាគី (ក) អាចលុបចោលកិច្ចសន្យានោះបានដែរឬទេ? យោងតាមមាត្រា៣៤៦ កថាខណ្ឌ១ ក្រមរដ្ឋប្បវេណី ២០០៧ចែងថា៖ (ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលភាន់ច្រឡំអាចលុបចោលកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ)។ ដូច្នេះភាគី (ក) អាចលុបចោលកិច្ចសន្យានោះ បាន។

**ឆន្ទៈទាមទារឲ្យកើតឡើងអានុភាពគតិយុត្តៈ**

(ក) មានបំណងទិញដីរបស់(ខ)ដែលមានទំហំ ៥០០០ម៉ែតការ៉េ ក្នុងតម្លៃ ១០០០០០ដុល្លាអាមេរិក។ តាមពិតទៅ (ខ) មានដីទំហំតែ២០០០ម៉ែតការ៉េតែប៉ុណ្ណោះ តែដោយភាគី (ក) ភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យា ដូច្នេះភាគី (ខ) អាចលុបចោលកិច្ចសន្យាលក់ទិញនេះបាន។[76]

**សកម្មភាពនៃការបង្ហាញៈ**

ភាគី (ក) បានដាក់ផ្លាកលក់ដីមួយកន្លែងក្នុងតម្លៃ ១០០០០០ ដុល្លាអាមេរិក។ ក្រោយមកភាគី (ខ) យល់ព្រមទិញដីនោះ ហើយក៏បានផ្ញើសារមកសុំទិញដីភាគី (ក) ក្នុងតម្លៃ១០០០០ ដុល្លាអាមេរិក។ ភាគី (ក) យល់ថា ភាគី (ខ) មានការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យា ភាគី (ក) អាចលុបចោលកិច្ចសន្យាទិញលក់ជាមួយភាគី(ខ) បាន។[77]

[76] មាត្រា៣៤៦ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[77] មាត្រា៣៤៦ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ការប្រើប្រាស់មាត្រានីមួយៗ ករណីលក់ទិញរថយន្ត**

**មូលហេតុដែលនាំឲមានឆន្ទៈខាងក្នុងៈ**

ចំណុចដែលភាគីម្ខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា។ ភាគី (ក) ទិញរថយន្តមួយពីភាគី (ខ) ដោយខ្លួនគិតថា រថយន្តនោះជារថយន្តរបស់តារាភាពយន្តល្បីល្បាញហូលីវូដម្នាក់។ ប៉ុន្តែក្រោយពីបានប្រគល់ប្រាក់ និងរថយន្តរួចមក ភាគី (ក) បាននិយាយថា ខ្លួនទិញរថយន្តនេះព្រោះរថយន្តនេះជារបស់អតីតតារាភាពយន្តហូលីវូដដែលគាត់ពេញចិត្តតែប៉ុណ្ណោះ។ ពេលខ្លះភាគី (ខ) បានប្រាប់ថា រថយន្ត មិនមែនរបស់តារាភាពយន្តល្បីល្បាញអីទេ គឺជារបស់គាត់តែម្តង។ ភាគី (ក) ស្រង៉ាកចិត្ត ហើយសុំលុបកិច្ចសន្យាលក់ទិញនេះវិញ។ តើភាគី (ក) អាចលុបចោលកិច្ចសន្យានេះបានដែរឬទេ? បើ «ក្នុងករណីដែលភាគីម្ខាង នៃកិច្ចសន្យាមានការភាន់ច្រឡំ នៃចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ថាសំខាន់ ឬចំណុចដែលខ្លួនយល់ថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និងការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។»[78] ដូចនេះភាគគី (ក) អាចលុបចោលកិច្ចសន្យាបាន។ មួយវិញទៀតបើ «ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុច សំខាន់ៗនៃកិច្ចសន្យាឬចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬចំណុចដែល ភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យាទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញ ឆន្ទៈនោះមានវិការៈ។»[79] ដូច្នេះភាគី (ក) ក៏អាចលុបចោលកិច្ចសន្យាបានដែរ។

**ឆន្ទៈទាមទារឲ្យកើតឡើងនូវអានុភាពគតិយុត្តៈ**

លោក (ក) បានទូរស័ព្ទសុំទិញរថយន្ត ឡិចស៊ីសពីលោក (ខ) ក្នុងតម្លៃ ១០000 ដុល្លារ ដែលភាគី (ខ) បានប្រកាសលក់។ តាមពិតលោក (ខ) ប្រកាសលក់រថយន្តស៊ីអរវី ទេក្នុងតម្លៃ ១០000 ដុល្លារនោះលោក (ខ) មិនមានរថយន្តឡិចស៊ីសដូចដែលលោក (ក)ចង់បាននោះទេ។ ដូច្នេះលោក (ខ) អាចលុបកិច្ចសន្យាលក់ទិញជាមួយលោក(ក)វិញបាន។[80] ក្នុងករណីស្រដៀងគ្នានេះដែរ លោក (ក) បានសុំទិញរថយន្តពីលោក (ខ) ក្នុងតម្លៃ ១០000 ដុល្លារ។ លោក (ក) ចង់ទិញរថយន្តដែលមានស្លាកលេខភ្នំពេញតែប៉ុណ្ណោះ ប៉ុន្តែលោក (ខ)

[78] មាត្រា៣៤៦ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[79] មាត្រា៣៤៦ កថាខណ្ឌទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[80] មាត្រា៣៤៦ កថាខណ្ឌទី១&៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

មិនមានរថយន្តដែលមានស្លាកលេខភ្នំពេញទេ គាត់មានតែរថយន្តដែលមានស្លាកលេខខេត្តកណ្តាល។ តើលោក (ក) អាចលុបចោលកិច្ចសន្យាលក់ទិញជាមួយលោក (ខ) បានដែរ ឬទេ?

ចំពោះ «ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំនៃចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ថាសំខាន់ ឬចំណុចដែលខ្លួនយល់ថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និងការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។»[81]

ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាព អាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[82] ដូច្នេះបើយោងតាមមាត្រា ៣៤៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ លោក (ក) អាចលុបកិច្ចសន្យាលក់ទិញរថយន្តពីលោក (ខ) វិញបាន។

**សកម្មភាពនៃការបង្ហាញ៖**

លោក (ក) ប្រកាសលក់រថយន្តរបស់គាត់ក្នុងតម្លៃ១០០០០ដុល្លារ ជាច្រើនថ្ងៃមកហើយ។ ក្រោយមកលោក (ខ) បានផ្ញើសារមកសុំទិញរថយន្តនោះក្នុងតម្លៃប្រកាសលក់ខាងលើ ប៉ុន្តែលោក (ខ) បានផ្ញើសារច្រឡំតម្លៃ ១០០០ដុល្លាទៅវិញ។ សួរថា តើលោក (ក) អាចលុបចោលកិច្ចសន្យាលក់ទិញនេះវិញបានដែរ ឬទេ? បើយោងតាមមាត្រា ៣៤៦ កថាខណ្ឌទី១ និងកថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ លោក (ក) អាចលុបកិច្ចសន្យាលក់ទិញនេះវិញបានទេ។

លោក (ក) ជាអ្នកលក់រថយន្តនៅភ្នំពេញ លោក(ខ) មានទីលំនៅ នៅខេត្តសៀមរាបបានឡើងមកទិញរថយន្តនៅភ្នំពេញ។ ថ្ងៃមួយលោក (ខ) បានមកជួបលោក (ក) ដើម្បីទិញរថយន្តពីលោក (ក)អ្នកទាំងពីរបានព្រមព្រៀងគ្នាលក់ទិញរថយន្តមួយគ្រឿងក្នុងតម្លៃសមរម្យ ដោយសន្យា៣ថ្ងៃក្រោយប្រគល់រថយន្ត និងប្រគល់លុយ។

ប៉ុន្តែ៣ថ្ងៃក្រោយលោក (ក) រង់ចាំលោក (ខ) ដើម្បីប្រគល់រថយន្តនៅភ្នំពេញ រីឯលោក (ខ) ក៏រង់ចាំលោក (ក) ដើម្បីប្រគល់ប្រាក់នៅខេត្តសៀមរាបផងដែរ។ អ្នកទាំងពីរបានយល់ច្រឡំពីទីកន្លែងប្រគល់រថ យន្ត។[83]

---

[81] មាត្រា៣៤៦ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[82] មាត្រា៣៤៦ កថាខណ្ឌទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[83] មាត្រា៣៤៦ កថាខណ្ឌទី២ & ៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## ៣.៤ វិធីនៃការលុបចោល ឬ សច្ចានុមតិ

ការលុបចោល និងសច្ចានុមតិ ត្រូវធ្វើឡើងតាមរយៈការជូនដំណឹងទៅភាគីម្ខាងទៀត។[84]

ការជូនដំណឹង ធ្វើឡើងដោយផ្ទាល់មាត់ក៏បាន ជាលិខិតក៏បាន។

អានុភាពនៃការលុបចោល និងសច្ចានុមតិកើតមានឡើង នៅពេលការជូនដំណឹង បានទៅដល់ភាគីម្ខាងទៀត។

(អាច ឬ មិនអាចនៃបណ្តឹងទាមទារលុបចោលកិច្ចសន្យា)

នៅក្នុងក្រិតច្បាប់ លេខ៣៨ បណ្តឹងទាមទារលុបចោលកិច្ចសន្យាអាចកើតឡើងបានដោយខ្លួនវា ផ្ទាល់។

ប៉ុន្តែ នៅក្នុងក្រមរដ្ឋប្បវេណីថ្មី នឹងក្រមនីតិវិធីរដ្ឋប្បវេណីវិញ បណ្តឹងទាមទារលុបចោលកិច្ចសន្យាមិនអាចលើកឡើង បានដោយខ្លួនវាផ្ទាល់ទេ ។ ពីព្រោះដោយគ្រាន់តែបានលុបកិច្ចសន្យា គឺមិនអាចសម្រេចគោលបំណងចម្បងដែលជា សំណងជាសាច់ប្រាក់ នឹងសំណងជាកម្មវត្ថុបានទេ ។ ដោយសារតែចុងក្រោយ នៅតែត្រូវដាក់ពាក្យបណ្តឹង ដើម្បីទាមទារសំណងជាសាច់ប្រាក់ និងសំណងជាកម្មវត្ថុមន្តទៀត។

ឧទាហរណ៍ នៅក្នុងកិច្ចសន្យាទិញលក់ដី ក្រោយពេលអ្នកទិញបានបង់ប្រាក់រួច កិច្ចសន្យាក៏ត្រូវលុបចោលដោយមូលហេតុការភាន់ច្រឡំ។ ក្នុងករណីនេះនៅក្រៅតុលាការ ពេលដែលអ្នកទិញបានជូនដំណឹងពីការភាន់ច្រឡំទៅកាន់អ្នកលក់ អានុភាពនៃការលុបចោល នឹងកើតឡើង។ ប៉ុន្តែប្រសិនបើ អ្នកលក់មិនព្រមទទួលស្គាល់ការលុបចោលរបស់អ្នកទិញ ហើយមិនព្រមសងប្រាក់នោះអ្នកទិញចាំបាច់ត្រូវដាក់ពាក្យប្តឹង។ ករណីនេះអ្នកទិញមិនមែនដាក់ពាក្យបណ្តឹងទាមទារលុបចោលកិច្ចសន្យានោះទេ គឺចាំបាច់ត្រូវដាក់ពាក្យបណ្តឹង ទាមទារសំណងជាសាច់ ប្រាក់។ ការលុបចោលកិច្ចសន្យា គឺជាវិធីសាស្ត្រក្នុងការការពារវាយប្រហារក្នុងវិវាទ ប៉ុន្តែមិនមែនជាគោលបំណងនៃពាក្យបណ្តឹងទេ។

### ៣.៤.១ អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ និងលក្ខខណ្ឌនៃការផ្តល់សច្ចានុមតិ

ក្នុងករណីការបង្ហាញឆន្ទៈមានវិការៈ អ្នកមានសិទ្ធលុបចោលអាចផ្តល់សច្ចានុមតិបានចាប់ពីពេលបានដឹងអំពីមូលហេតុនៃការលុបចោល (កថាខណ្ឌទី១)។[85]

**ករណីសិក្សា**

ក ត្រូវបាន ខ បោកបញ្ឆោតថា ដី x ច្បាស់ជាឡើងថ្លៃក្នុងរយៈពេល១ឆ្នាំ ។ ក ក៏បានបង្កើតកិច្ចសន្យាទិញដី x ពី ខ និងធ្វើលិខិតយថាភូត ។ ខ បានសួរទៅកាន់ ក ថា "អាចលុបចោលកិច្ចសន្យាពីឥឡូវបាន តើគិតយ៉ាងណា?" នៅពេលនោះ ក មិនទាន់បានដឹងពីការបោកបញ្ឆោតរបស់ ខ រួចក៏តបថា " ទេ មិនចាំបាច់លុបចោលទេ " ក្រោយមក កន្លងផុតទៅ១ឆ្នាំ តំលៃដី x មិនឡើងថ្លៃ ក គិតថាត្រូវបាន ខ បោកប្រាស់ ក៏បានដាក់ពាក្យបណ្តឹងលុប

[84] មាត្រា៣៦០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[85] មាត្រា៣៦១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ចោលកិច្ចសន្យាដោយមូលហេតុឆបោក និងទាមទារសំណងជាសាច់ប្រាក់ពី ខ ។ ក្នុងវិវាទ ខ បានអះអាងថា "ដោយសារតែ ក បានផ្តល់សច្ចានុមតិថា មិនចាំបាច់លុបចោលកិច្ចសន្យា ហេតុនេះកិច្ចសន្យា មិនអាចលុបចោលបានទេ ។" ការអះអាងរបស់ ខ មិនអាចទទួលយកបានទេ ។ពីព្រោះពេលដែល ក ឆ្លើយតបទៅ ខ ក មិនបានដឹងថាមានមូលហេតុនៃការលុបចោល ហេតុនេះសកម្មភាពរបស់ ក មិនក្លាយជាសច្ចានុមតិទេ។

ករណីកង្វះសមត្ថភាពខាងឆន្ទៈ ឬ ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព អាចផ្តល់សច្ចានុមតិបាននៅក្រោយដែលស្ថានភាពដែលជាមូលហេតុនៃការលុបចោលត្រូវបានរលត់ (ក១)។ ឧទាហរណ៍ ករណីអនីតិជនបើមិនទាន់ក្លាយជាជនគ្រប់អាយុ មិនអាចផ្តល់សច្ចានុមតិបានទេ។ ប៉ុន្តែចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ និងហិតូបត្ថម្ភកៈ ទោះជាអ្នកបង្ហាញឆន្ទៈអសមត្ថភាពខាង ឆន្ទៈ ឬ អសមត្ថភាពខាងសកម្មភាពក៏អាចផ្តល់សច្ចានុមតិបានដែរ (ក២)។

### ៣.៤.២ សច្ចានុមតិដែលច្បាប់បានកំណត់

ទោះជាមិនមានការជូនដំណឹងច្បាស់លាស់ក៏ដោយ ប្រសិនមានបើមានអង្គហេតុដូចខាងក្រោម នឹងត្រូវចាត់ទុកថា បានផ្តល់សច្ចានុមតិរួចហើយ។ ព្រោះថា ប្រសិនមានអង្គហេតុដូចខាងក្រោម ភាគីម្ខាងទៀតនឹងរំពឹងទុកថា កិច្ចសន្យានឹងមិនត្រូវបានលុបចោលទេ ការរំពឹងទុកបែបនេះចាំបាច់ត្រូវការពារ។

ការអនុវត្តកាតព្វកិច្ចទាំងមូល ឬ មួយផ្នែក ចំពោះកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពដែលអាចលុបចោលបាន ឬ ការដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ចនោះ (ចំណុច ក)។

**ករណីសិក្សា**

ក មានបំណងទិញរថយន្ត Lexus ពីអ្នកស្គាល់គ្នា ខ ប៉ុន្តែបានច្រឡំទិញរថយន្ត CRV ទៅវិញ។ ក បានគិតថា ចង់លុបចោលកិច្ចសន្យាដោយមូលហេតុការភាន់ច្រឡំ ប៉ុន្តែមិត្តស្រីរបស់គាត់ គ បាននិយាយថា "ខ្ញុំចូលចិត្តរថយន្ត CRV ជាងរថយន្ត Lexus"។ ក ក៏មិនបានលុបចោលកិច្ចសន្យាហើយប្រគល់ប្រាក់ឲ្យ ខ ។ ប៉ុន្តែក្រោយមក ក បានបែកគ្នាជាមួយ គ ហើយចាប់ផ្តើមសេពគប់ជាមួយ ឃ ជាមិត្តស្រីថ្មី ។ ដោយសារតែ មិត្តស្រី ឃ បាននិយាយថា "រថយន្ត Lexus ឡូយជាង រថយន្ត CRV " ក គិតថាទិញរថយន្ត Lexus ក៏បានជូនដំណឹងលុបចោលកិច្ចសន្យាទៅ ខ និងទាមទារសំណងជាសាច់ប្រាក់ ។ ករណីបែបនេះ ការបង់ប្រាក់របស់ ក ត្រូវបាន ចាត់ទុក ជាសច្ចានុមតិ ហេតុនេះ ខ អាចបដិសេធមិនសងសំណងជាប្រាក់ បាន។

- ការអនុវត្តសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ឬ ការទាម ទារឲ្យភាគីម្ខាងទៀតអនុវត្ត (ចំណុច ខ) ។
- អនុប្បទាន ឬ ការចាត់ចែងផ្សេងទៀតនូវសិទ្ធិទាំងមូល ឬ មួយផ្នែក ចំពោះសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ។

• ប៉ុន្តែ ករណីដែលបានសំដៅទុកជាមុនថា មិនផ្តល់សច្ចានុមតិ នោះមិនត្រូវបានចាត់ទុកថាបាន ផ្តល់សច្ចានុមតិទេ ។

**ករណីសិក្សា**

ក មានបំណងទិញរថយន្ត Lexus ពីស្គាល់គ្នា ខ ប៉ុន្តែបានច្រឡំទិញរថយន្ត CRV ទៅវិញ ។ ក បានគិតថា នឹងសួរយោបល់ពីមិត្តស្រីរបស់គាត់ គ ថាគួរតែលុបចោល កិច្ចសន្យាដោយមូលហេតុការភាន់ច្រឡំ ឬទេ រួចទើបធ្វើការសម្រេចចិត្ត ។ ហើយនៅពេលដែល ត្រូវបាន ខ ទាមទារឲ្យបង់ប្រាក់ ក បាននិយាយថា " ខ្ញុំបង់ប្រាក់ឲ្យជាមុនសិន ប៉ុន្តែ ប្រសិនបើ មិត្តស្រីរបស់ខ្ញុំនិយាយថា ចង់ជិះរថយន្ត Lexus កិច្ចសន្យានឹងត្រូវលុបចោល" រួចក៏បាន បង់ប្រាក់ ។ ក្រោយមក បន្ទាប់ពីបានស្តាប់គំនិតមិត្តស្រី គ រួច នាងបានឆ្លើយថា "ចង់ជិះរថយន្ត Lexus ជាងរយន្ត CRV "។ ពេលនោះ ក ក៏បានជូនដំណឹងលុបចោលកិច្ចសន្យា ទៅ ខ និងទាមទារសំណងជាប្រាក់ ។ ករណីនេះ ខ មិនអាចបដិសេធមិនផ្តល់សំណងជាប្រាក់បានទេ។

**៣.៤.៣ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល**

• សិទ្ធិលុបចោល នឹងត្រូវរលត់ក្នុងរយៈពេល៣ឆ្នាំ ចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិ(ក១)។[86] សិទ្ធិទាមទារឲ្យសងសេចក្តីចម្រើនដោយឥតហេតុដែលកើតឡើង ដោយសារការលុបចោលនោះក៏ត្រូវរលត់ដែរ (ក១) ។

• ម៉្យាងទៀត ទោះបីជាមិនស្ថិតក្នុងស្ថានភាពអាចផ្តល់សច្ចានុមតិក៏ដោយ ប្រសិនបើហួសអំឡុងពេល១០ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាព នោះសិទ្ធិលុបចោលក៏ត្រូវរលត់ដែរ (ក២)។

• ក្នុងករណីដែលមានបុគ្គលច្រើននាក់មានសិទ្ធិលុបចោល បញ្ញត្តិនៃកថាខណ្ឌទី១ នឹងទី២ ខាងលើនេះត្រូវយកមកអនុវត្ត ចំពោះសិទ្ធិលុបចោលនីមួយៗ(ក៣) ។

**ករណីសិក្សា**

ក គឺជាអនីតិជន មានអាយុ១៦ឆ្នាំ ហើយ ខ គឺជាអ្នកតំណាងដែលច្បាប់បានកំណត់ ។ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ក បានបង្កើតកិច្ចសន្យាទិញលក់រថយន្តជាមួយ គ ។ក បានក្លាយជាជនគ្រប់អាយុ ១៨ឆ្នាំ នៅថ្ងៃកំណើតថ្ងៃទី១០ ខែសីហា ឆ្នាំ ២០១៦ ។ ក្នុងករណីជាកូន ដោយសារ ខ ជាឪពុកអាចអនុវត្តសិទ្ធិសច្ចានុមតិ ចាប់ពីពេលបង្កើតកិច្ចសន្យារបស់ ក សិទ្ធិលុបចោលរបស់ ខ ជាឪពុក នឹងរលត់រយៈពេល៣ឆ្នាំ បន្ទាប់ពីថ្ងៃបង្កើតកិច្ចសន្យា នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ ។ ដោយសារតែ ក អាចអនុវត្តសិទ្ធិផ្តល់សច្ចានុមតិ ចាប់ពីថ្ងៃកំណើតអាយុ ១៨ឆ្នាំ នោះ សិទ្ធិលុបចោលរបស់ ក នឹងត្រូវរលត់រយៈពេល ៣ឆ្នាំ បន្ទាប់ពីថ្ងៃកំណើតអាយុ ១៨ឆ្នាំ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៩ ។

[86] មាត្រា៣៦៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើកិច្ចការស្រាវជ្រាវទៅលើប្រធានបទនេះ ក៏ដូចជាបានធ្វើការរៀបរាប់យ៉ាងក្បោះក្បាយពីខាងលើរួចមកហើយ យើងអាចធ្វើការសន្និដ្ឋានបានថាៈ សុពលភាពនៃកិច្ចសន្យា គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់កិច្ចសន្យានីមួយៗដែលបានបង្កើតឡើង ព្រោះដោយចំណុចសំខាន់ យើងត្រូវដឹងថា ដើម្បីបង្កើតកិច្ចសន្យាមួយទៅបាន លុះត្រាតែមានការបង្ហាញឆន្ទៈពីភាគីម្ខាង ទៅភាគីម្ខាងទៀត។ ពោលគឺ ការបង្កើតកិច្ចសន្យាគឺ ជាការបង្កើតការព្រមព្រៀងគ្នាទៅវិញទៅមករវាងគូភាគីពីរ ឬច្រើន នាក់។ ម្យ៉ាងវិញទៀត យើងក៏អាចនិយាយបានថា ការបង្កើតកិច្ចសន្យាទៅបានទាល់តែសំណើ និងស្ទីការនោះត្រូវគ្នា។ ដោយបានដឹងជារឿយៗហើយថា ក្នុងកិច្ចសន្យានីមួយៗភាគច្រើនតែងតែមានការភ័ន្តច្រឡំនេះភ័ន្តច្រឡំនោះ ហើយការភ័ន្តច្រឡំទាំងអស់នេះ គឺអាចមកពីភាគីជាអ្នកដាក់សំណើ ហើយនិងពេលខ្លះទៀតគឺអាចមកពីភាគីដែលបានយល់ព្រមទទួលសំណើ។ បន្ថែមពីនេះទៅទៀត រាល់កិច្ចសន្យានីមួយៗតែងតែមានការកំណត់នូវរយៈយ៉ាងជាក់លាក់ ព្រោះការកំណត់ពេលវេលាក្នុងកិច្ចសន្យានេះ គឺជាកត្តាចម្បងមួយដែលធ្វើឲភាគីទាំងពីរបានគោរពនូវកាតព្វកិច្ចរបស់ខ្លួនយ៉ាងម៉ឺងម៉ាត់ (ជាពិសេសគឺកូនបំណុល) ដើម្បីឲកិច្ចសន្យាមួយនោះមានសុពលត្រឹមត្រូវតាមផ្លូវគតិយុត្តិ។ ផ្ទុយពីនេះចំពោះការបង្កើតកិច្ចសន្យា ជាញឹកញាប់ក៏តែងតែជួបនូវផលពិបាកមួយចំនួនផងដែរ ដែលយើងតែងតែប្រទះឃើញថាគឺជា វិការៈក្នុងការបង្ហាញឆន្ទៈដែលតែងតែមានការភ័ន្តច្រឡំជាច្រើនបែបច្រើន សន្ធាន។ នៅក្នុងរឿងក្តីបែបវិការៈក្នុងការបង្ហាញឆន្ទៈ តើត្រូវពិចារណាលើផលប្រយោជន៍របស់អ្នកណា? ដោយទិដ្ឋភាពទាំងអស់នៃការលុបចោលកិច្ចសន្យា ដែលរៀបរាប់កិច្ចសន្យាអាចត្រូវបានលុបចោល ដោយសារមានវិការៈក្នុងការបង្ហាញឆន្ទៈ។ មិនត្រឹមតែប៉ុណ្ណោះ នៅក្នុងសង្គមជាក់ស្តែងនាពេលបច្ចុប្បន្ននេះ ជាញឹកញយតែងតែប្រទះឃើញថាភាគច្រើនមានទំនាស់នានាក្នុងកិច្ចសន្យាមួយចំនួនធំដូចជា សេចក្តីចម្រើនឥតហេតុ ការគេងប្រវ៉ាញ់ ការគម្រាមកំហែងដោយឋានៈបុគ្គល ការភ័ន្តច្រឡំលើខ្លឹមសារនៃកិច្ចសន្យា និងអាចមានភាពវិការៈផ្សេងទៀតជាច្រើនទៅតាមទិដ្ឋភាពជាក់ស្តែង។

កិច្ចសន្យាមានសុពលភាព គឺពេលការបង្ហាញ ឆន្ទៈរបស់ភាគីទាំងពីរស្របគ្នាទៅវិញទៅមក ដូច្នេះហើយប្រសិនបើគ្មានការបង្ហាញឆន្ទៈដែលមានអានុភាពដែលជាធាតុផ្សំនៃកិច្ចសន្យាទេ កិច្ចសន្យាពុំមានចំណងសម្រាប់ធ្វើការចងភាគីទាំងពីរនោះទេ បើទោះបីជាកិច្ចសន្យាហាក់ដូចជាត្រូវបានបង្កើតឡើងបើមើលពីខាងក្រៅក៏ដោយ។ បន្ថែមពីនេះទៅទៀត ការបង្ហាញឆន្ទៈដែលមានសុពលភាព គឺជាលក្ខខ័ណ្ឌមួយដើម្បីឲ្យកិច្ចសន្យាមានអានុភាពចងភាគីទាំងពីរ ដែលបានចែងក្នុងមាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ កត្តាដែលសំខាន់មួយទៀតគឺ ការកំណត់ពេលវេលាឲបានត្រឹមត្រូវនៅពេលដែលចាប់ផ្តើមបង្កើតកិច្ចសន្យា ព្រោះក្នុងករណីដែលមានកំណត់ពេលចាប់ផ្តើម ចំពោះការអនុវត្តកិច្ចសន្យា ដោយម្ចាស់បំណុលមិនអាចទាមទារឲកូនបំណុលអនុវត្តកាតព្វកិច្ច មុនពេលកំណត់បាន ឡើយ។ ចំពោះការកំណត់ពេលវេលាឲ្យបានជាក់លាក់នេះ គឺជាចំណុចមួយដែលមានផល

ប្រយោជន៍ ដោយប្រយោជន៍នៃការកំណត់ពេលនេះអាចបោះបង់ចោលបាន លុះត្រាតែមិននាំឲ្យមានការខូចខាតដោយមិនត្រឹមត្រូវ ដល់ភាគីម្ខាងទៀត។ ប៉ុន្តែ យើងក៏ចាំបាច់ត្រូវដឹងដែលថា ប្រសិនបើការបោះបង់ចោលនោះធ្វើឲមានការខូចខាតផលប្រយោជន៍របស់ភាគីម្ខាងទៀត ភាគីដែលធ្វើឲមានការខូចខាតនោះ ត្រូវតែធ្វើការសងការខូចខាតដល់ភាគីម្ខាងទៀត។

ជារួម ក្នុងគោលការណ៍គតិយុត្ត ដើម្បីឲ្យកិច្ចសន្យាមួយអាចមានសុពលភាពនៃកិច្ចសន្យានោះបាន គឺត្រូវតែបំពេញឲ្យបានខ្ជាប់ខ្ជួននូវលក្ខខណ្ឌចាំបាច់ដូចជា សំណើ និងស្ទីការត្រូវគ្នា និងលក្ខខណ្ឌគ្រប់គ្រាន់គឺមានលក្ខខណ្ឌទូទៅទាក់ទងនឹងភាគីដែលរួមមានសមត្ថភាពទទួលសិទ្ធិ សមត្ថភាពខាងឆន្ទៈ សមត្ថភាពក្នុងការធ្វើសកម្មភាព និងគ្មានវិការៈក្នុងការបង្ហាញឆន្ទៈ និង លក្ខខណ្ឌទូទៅទាក់ទងនឹងខ្លឹមសារនៃកិច្ចសន្យាដែលរួមមានភាពច្បាស់លាស់ ភាពស្របច្បាប់ ភាពសមស្របតាមស្ថានភាពសង្គម និងភាពគ្មានការបង្ហាញឆន្ទៈមិនពិត។

# អនុសាសន៍

យើងបានសង្កេតដឹងហើយថា នៅក្នុងទំនាក់ទំនងនៃការបង្កើតកិច្ចសន្យាឲ្យស្របតាមចំណងគតិយុត្ត នីមួយៗ គឺត្រូវកំណត់ដោយច្បាប់ជាកំហិត។ ជាពិសេសទៅទៀតនោះ កិច្ចសន្យាមានច្រើនប្រភេទ និងច្រើនទម្រង់ណាស់ តែយើងត្រូវដឹងថា ចំពោះកិច្ចសន្យានីមួយៗដែលអាចបង្កើតឡើងទៅបាន គឺត្រូវបានពិនិត្យទៅលើកម្មវត្ថុនៃកិច្ចសន្យានោះ ព្រោះដោយសារកិច្ចសន្យានីមួយៗតែងតែមានចំណុចមិនដូចគ្នាជាច្រើន ពោលគឺ ចំណុចពិសេសដែលយើងត្រូវពិនិត្យមើលឲ្យបានច្បាស់លាស់ គឺ លក្ខណៈទម្រង់ ហើយនិងលក្ខណៈគ្រឹះ។ បន្ថែមពីនេះទៅទៀត ចំពោះកិច្ចសន្យាដែលបានបង្កើតឡើងនោះ គឺភាគច្រើនតែងតែមានការភ័ន្តច្រឡំទៅលើកម្មវត្ថុ ហើយពេលខ្លះកិច្ចសន្យាទាំងនោះបានកើតមានវិការៈជាច្រើនផងដែរ។ ដោយម្យ៉ាងវិញទៀត យើងអាចសង្កេតមើលទៅជនដែលច្បាប់បានកម្រិតសម្ថភាព ដោយជនទាំងនោះមានដូចជា ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ និងជនដែលមិនទាន់គ្រប់អាយុក្នុងភាពដែលអាចធ្វើកិច្ចសន្យាបាន។ ដូចដែលបានយល់ហើយ ចំពោះជនខាងលើដែលបានរៀបរាប់នេះ គឺមិនអាចធ្វើការបង្កើត ឬរំលត់នូវកិច្ចសន្យាបានដោយខ្លួនឯងបានឡើយ លុះត្រាតែកិច្ចសន្យានោះមានការយល់ស្រប ឬឯកភាពពីសំណាក់អាណាព្យាបាល អាណាព្យាបាលទូទៅ និងហិតូបត្ថម្ភកៈ ទើបកិច្ចសន្យានោះអាចមានអានុភាពទៅបានស្របតាមនីតិវិធីច្បាប់ដែលបានកំណត់ និងជាធរមាន។

កិច្ចសន្យាដែលអាចមានសុពលភាពទៅបាន លុះត្រាតែកិច្ចសន្យានោះ មានឆន្ទៈស្របគ្នាទៅវិញទៅមក ដោយភាគីអ្នកទទួលសំណើ បានយល់ព្រមនូវការដាក់សំណើពីភាគីម្ខាងទៀត ពោលគឺ សំណើ និងស្ទីការត្រូវគ្នាដែលឆន្ទៈនៃភាគីទាំងទ្វេនោះមានអានុភាពដែលជាធាតុផ្សំនៃកិច្ចសន្យាទៅបាន។ បន្ថែមពីនេះទៅទៀត ចំពោះការបង្ហាញឆន្ទៈដែលមានសុពលភាព គឺជាលក្ខខ័ណ្ឌមួយដើម្បីឲ្យកិច្ចមានអានុភាពចងភាគីទាំងពីរ ដែលបានចែងក្នុងមាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ តែជារឿយៗ ដោយយើងបានឃើញហើយ គឺមានកិច្ចសន្យាជាច្រើនដែលបានបង្កើតឡើងហើយ ប៉ុន្តែតែងតែមានភាពមិនប្រក្រតី ពោលគឺ វិការៈនៅក្នុងកិច្ចសន្យា។ ដោយសារតែការរស់នៅប្រចាំថ្ងៃ យើងអាចសង្កេតឃើញថា ប្រជាពលរដ្ឋនៅក្នុងសង្គមខ្មែរគឺបានបង្កើតទំនាក់ទំនងបែបផ្លូវច្បាប់ដោយបង្កើតកិច្ចសន្យាជាប្រចាំថ្ងៃ និងស្ទើរគ្រប់ទីកន្លែង មិនថាទីប្រជុំជន ឬជាយក្រុង។

ចំពោះលក្ខខ័ណ្ឌក្នុងការបង្កើតកិច្ចសន្យាក្នុងបែបបទគតិយុត្ត គឺគេតម្រូវឲ្យសំណើ និងស្ទីការត្រូវគ្នាសិន ហើយបន្ទាប់ពីត្រូវគ្នា ភាគីទាំងពីរអាចបន្តឆន្ទៈនៃកិច្ចសន្យានោះបានដោយមានការព្រមព្រៀងគ្នា ហើយកិច្ចសន្យានោះត្រូវតែបង្កើតឡើងជាលាយល័ក្ខអក្សរ ហើយកិច្ចសន្យាខ្លះទៀតតម្រូវបង្កើតនូវលិខិតយថាភូតពីការព្រមព្រៀងគ្នារវាងភាគីទាំងសងខាង គឺជាការចំបាច់ណាស់ ដោយមូលហេតុថា កិច្ចសន្យាមួយដែលអាចហៅថាកិច្ចសន្យាដែលស្របតាមផ្លូវគតិបាន និងមានសុពលភាពត្រឹមត្រូវ លុះត្រាតភាគីទាំងពីរនោះបានគោរពប្រតិបត្តិតាមនូវលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់នៅក្នុងដំណាក់កាល ពេលដែលបង្កើតកិច្ចសន្យា។

# ឯកសារយោង


១. ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០ ភ្នំពេញ ថ្ងៃទី ៨ ធ្នូ ឆ្នាំ២០០៧

២. ក្រមនីតិវិធីរដ្ឋប្បវេណី បោះពុម្ព ភ្នំពេញ ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៧

៣. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ១ដល់៦ ភ្នំពេញ (ឆ្នាំ២០១០)

៤. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ភ្នំពេញ (ឆ្នាំ២០១១)

៥. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីបណ្តឹង ភ្នំពេញ (ឆ្នាំ២០០៨)

៦. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២៖ អំពីការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ ភ្នំពេញ (ឆ្នាំ២០០៩)

៧. ក្រសួងយុត្តិធម៌៖ មេរៀន ក្រមរដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ភាគ១ ភ្នំពេញ (ឆ្នាំ២០១៥)

៨. ក្រសួងយុត្តិធម៌៖ មេរៀន ក្រមរដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ភាគ២-៣ ភ្នំពេញ (ឆ្នាំ២០១៧)

៩. ណូមារ៉ា តូយ៉ូហ៊ីរ៉ូ៖ សេចក្តីនីតិរដ្ឋប្បវេណី បោះពុម្ព លើកទី៥ ភ្នំពេញ (ឆ្នាំ២០១១)

១០. គាម ម៉ារិទ្ធីយ៉ា៖ នីតិរដ្ឋប្បវេណី (ឆ្នាំ២០១៥)

# ឧបសម្ព័ន្ធទី១

## ជំពូកទី ២
## ការបង្ហាញឆន្ទៈ និង កិច្ចសន្យា

### ផ្នែកទី ១
### ការបង្កើតកិច្ចសន្យា

**មាត្រា ៣៣៦.–** ការបង្កើតកិច្ចសន្យាដោយសំណើ និង ស្វីការ

១-កិច្ចសន្យាមានអានុភាពដោយសារសំណើ និង ស្វីការត្រូវគ្នា ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទានទ្រព្យសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មទ្រព្យសិទ្ធិលើអចលនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត ។

**មាត្រា ៣៣៧.–** និយមន័យនៃសំណើ និង ស្វីការ

១-សំណើគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ ។

២-សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើដល់ ឬ មុនពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតឡើយ ។

៣-ស្វីការគឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ ។

៤-ស្វីការត្រូវមានអានុភាពនៅពេលដែលស្វីការនោះបានដល់អ្នកស្នើ ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកស្វីការវិញ ដល់អ្នកស្នើ នៅពេលព្រមគ្នានឹងពេលស្វីការដល់ ឬ មុនពេលស្វីការដល់ នោះអានុភាពនៃស្វីការ មិនត្រូវកើតឡើយ ។

**មាត្រា ៣៣៨.–** សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្វីការ និង ការដកសំណើនោះ

១-សំណើអាចធ្វើឡើងបានដោយកំណត់អំឡុងពេលសម្រាប់ស្វីការ ។ អំឡុងពេល

១២៣

សម្រាប់ស្វីការ ត្រូវគិតចាប់ពីថ្ងៃដែលជូនដំណឹងអំពីសំណើ បើមិនច្បាស់ថា អ្នកស្នើកំណត់ពេលផ្សេង ។

២-សំណើដែលត្រូវបានធ្វើឡើងដោយមានកំណត់អំឡុងពេលសម្រាប់ស្វីការ មិនអាចដកវិញបានទេ ។

៣-ប្រសិនបើអ្នកស្នើមិនបានទទួលដំណឹងអំពីស្វីការ ក្នុងអំឡុងពេលដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះទេ សំណើនោះត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិនៅពេលផុតអំឡុងពេលសម្រាប់ស្វីការ ។ ក្នុងករណីដែលដំណឹងអំពីការបដិសេធសំណើបានដល់អ្នកស្នើក្នុងអំឡុងពេលសម្រាប់ស្វីការនោះ សំណើនោះក៏ត្រូវបាត់បង់អានុភាពដែរ ។

**មាត្រា ៣៣៩.–** សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ និង ការដកសំណើនោះ

១-ចំពោះសំណើដែលត្រូវបានធ្វើឡើងដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការរវាងគូភាគីដែលកំពុងនិយាយគ្នា នៅក្នុងស្ថានភាពដែលអាចឆ្លើយភ្លាមៗបាន ប្រសិនបើភាគីដែលទទួលសំណើមិនបានយល់ព្រមភ្លាមៗទេ សំណើនោះត្រូវបាត់បង់អានុភាព ។

២-ចំពោះសំណើដែលធ្វើរវាងគូភាគីដែលមិននិយាយគ្នា ដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការទេ អ្នកស្នើមិនអាចដកសំណើនោះវិញក្នុងអំឡុងពេលសមរម្យបានឡើយ ។

៣-ការដកសំណើត្រូវមានអានុភាព លុះត្រាតែការជូនដំណឹងអំពីការដកសំណើនោះបានមកដល់ភាគីម្ខាងទៀត មុនពេលភាគីម្ខាងទៀតជូនដំណឹងអំពីស្វីការ ។

**មាត្រា ៣៤០.–** ពេលនៃការបង្កើតកិច្ចសន្យា : គោលការណ៍នៃការមកដល់នៃស្វីការ

កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលដំណឹងអំពីស្វីការបានមកដល់អ្នកស្នើ ។

**មាត្រា ៣៤១.–** ការមកដល់យឺតយ៉ាវនៃស្វីការ

១-ក្នុងករណីដែលការជូនដំណឹងអំពីស្វីការ ចំពោះសំណើដែលមានអំឡុងពេល

១២៤

សម្រាប់ស្ទីការ មកដល់ភាគីម្ខាងទៀត ក្រោយពេលអំឡុងពេលសម្រាប់ស្ទីការនោះកន្លងផុត ប្រសិនបើអ្នកស្នើស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងថា ភាគីម្ខាងទៀតជូនដំណឹងអំពីស្ទីការនោះ នៅពេលដែលអាចមកដល់ក្នុងអំឡុងពេលសម្រាប់ស្ទីការក្នុងករណីធម្មតា នោះអ្នកស្នើត្រូវជូនដំណឹងអំពីការមកដល់ស្ទីការដោយមានការយឺតយ៉ាវនោះ ទៅអ្នកធ្វើស្ទីការ ដោយគ្មានការយឺតយ៉ាវ ។ ក្នុងករណីដែលអ្នកស្នើធ្វេសប្រហែសក្នុងការជូនដំណឹងអំពីការមកដល់ស្ទីការដោយមានការយឺតយ៉ាវនោះ ស្ទីការដែលមកដល់ដោយមានការយឺតយ៉ាវនោះ មានសុពលភាព ។

២-អ្នកស្នើ អាចចាត់ទុកថា ស្ទីការដែលបានមកដល់អ្នកស្នើក្រោយពេលផុតអំឡុងពេលសម្រាប់ស្ទីការ ជាសំណើថ្មី ។

**មាត្រា ៣៤២.-** ស្ទីការដោយមានបន្ថែមការកែប្រែ

១-ស្ទីការដែលអ្នកធ្វើស្ទីការបានដាក់ល័ក្ខខ័ណ្ឌលើសំណើ ឬ កែប្រែសារធាតុផ្សេងនៃសំណើ មិនត្រូវក្លាយជាស្ទីការសុពល តែស្ទីការនោះមានអានុភាពជាសំណើថ្មី ។ កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលអ្នកធ្វើសំណើដើម ធ្វើស្ទីការចំពោះសំណើថ្មីនោះ ។

២-ប្រសិនបើល័ក្ខខ័ណ្ឌ ឬ ការកែប្រែដែលភ្ជាប់ជាមួយនឹងស្ទីការមិនធ្វើឱ្យមានការកែប្រែសារធាតុនៃសំណើទេ ស្ទីការនោះមានសុពលភាព លុះត្រាតែអ្នកស្នើមិនតវ៉ាភ្លាម ។ អត្ថន័យនៃកិច្ចសន្យាដែលត្រូវកើតឡើងដោយស្ទីការនោះ ត្រូវទៅតាមអត្ថន័យនៃស្ទីការ លុះត្រាតែអ្នកស្នើដែលបានទទួលស្ទីការមិនតវ៉ាភ្លាមៗទេ ។

**មាត្រា ៣៤៣.-** ការបង្កើតកិច្ចសន្យាដោយសកម្មភាពដែលត្រូវបានចាត់ទុកថាជាស្ទីការ

ក្នុងករណីដែលមិនចាំបាច់ឱ្យមានដំណឹងអំពីស្ទីការ ដោយសារឆន្ទៈរបស់អ្នកស្នើ ឬ ដោយសារទំនៀមទម្លាប់នៃកិច្ចការជំនួញ កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលមានសកម្មភាពអាចទទួលស្គាល់ថាជាស្ទីការ ។

**មាត្រា ៣៤៤.-** ការដកសំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់

សំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់តាមការផ្សាយជាសាធារណៈ

# ឧបសម្ព័ន្ធទី២

ឬ តាមវិធីផ្សេងទៀត អាចដកបានតែតាមវិធីដូចគ្នានឹងសំណើនោះ ។

## ផ្នែកទី ២
## វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា

**មាត្រា ៣៤៥.–** ការបង្ហាញឆន្ទៈដែលមានវិការៈ

អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ តាមបញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) នេះ និង ផ្នែកទី ៣ (មោឃភាព និង ការលុបចោល) ក្នុងករណីដូចខាងក្រោមនេះ :

ក-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ។

ខ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោក ឬ ការគម្រាមកំហែង ឬ ការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត ។

គ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ ។

**មាត្រា ៣៤៦.–** ការភាន់ច្រឡំ

១-ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និង ការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

៣-ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

៤-ការលុបចោលនូវកិច្ចសន្យាដោយការភាន់ច្រឡំ ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំ មិនអាចអះអាងនូវការលុបចោលចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៧.–** ការឆបោក

១-បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ លុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះ បានដឹង ឬ អាចដឹងអំពីការឆបោកនោះ ។

៣-ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៨.–** ព័ត៌មានមិនពិត

១-នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត ប៉ុន្តែ ប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមាន

វិការៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងភាគីដែលបានបង្ហាញឆន្ទៈក្នុងការទាមទារសំណងនៃការខូចខាតពីបុគ្គលដែលបានបង្ហាញការណ៍មិនពិតនោះទេ ក្នុងករណីដែលបុគ្គលនេះមានកំហុស ។

៣-ការលុបចោលនូវកិច្ចសន្យាដោយព័ត៌មានមិនពិត ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីព័ត៌មានមិនពិត មិនអាចអះអាងនូវអានុភាពនៃការលុបចោល ចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៩.–** ការរំលោភបំពានលើស្ថានភាព

១-នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ការលុបចោលនូវកិច្ចសន្យាដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពានលើស្ថានភាពបានឡើយ ។

**មាត្រា ៣៥០.–** ការគម្រាមកំហែង

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

**មាត្រា ៣៥១.–** អំពើកេងយកចំណេញហួសហេតុ

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍ ហើយ

១២៨

បានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

**មាត្រា ៣៥២.-** ឋបនីយផ្លូវចិត្ត

ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈដែលភាគីដឹងខ្លួនថាខុសឆន្ទៈពិតរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរារាំងនូវអានុភាពឡើយ ។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងទៀតក៏ដឹងថាការបង្ហាញឆន្ទៈនោះ ខុសនឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដែរ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន ។

**មាត្រា ៣៥៣.-** ការបង្ហាញឆន្ទៈមិនពិត

១-កិច្ចសន្យា ដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតដែលត្រូវបានធ្វើឡើង ដោយមានការឃុបឃិតជាមួយនឹងភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ ។

២-មោឃភាពនៃកិច្ចសន្យាដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយយកកិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះជាជនទុច្ចរិត ឬ មិនបានដឹងអំពីការបង្ហាញនូវឆន្ទៈមិនពិតដោយមានកំហុសធ្ងន់ធ្ងរ ។

**មាត្រា ៣៥៤.-** ភាពខុសច្បាប់ ឬ ភាពផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ក្នុងអត្ថន័យនៃកិច្ចសន្យា

១-ទោះបីជាភាគីនៃកិច្ចសន្យាបានធ្វើការបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈ ក្នុងករណីខាងក្រោមនេះ :

ក-អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ ។

ខ-អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ។

២-ប្រសិនបើអត្ថន័យនៃកិច្ចសន្យាមានផ្នែកណាមួយដែលផ្ទុយនឹងបញ្ញត្តិដែល

អនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ហើយទោះបីជាទុកផ្នែកផ្សេងទៀត ក៏មិនធ្វើឱ្យខូចសេចក្តីសង្ឃឹមសមហេតុសមផលរបស់គូភាគីទេ នោះមានតែចំណុចដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អតែប៉ុណ្ណោះទេ ដែលត្រូវទុកជាមោឃៈ ។

**មាត្រា ៣៥៥.–** អលទ្ធភាពតាំងពីដំបូង

១-ទោះបីជាអត្ថន័យនៃកិច្ចសន្យាមិនអាចសម្រេចបានតាំងពីពេលដែលបង្កើតកិច្ចសន្យានោះក៏ដោយ ក៏កិច្ចសន្យានោះមិនត្រូវបានចាត់ទុកជាមោឃៈដោយយកមូលហេតុនៃអលទ្ធភាពនោះដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងភាគីក្នុងការលុបចោលនូវកិច្ចសន្យាដោយយកមូលហេតុនៃការភាន់ច្រឡំឡើយ ក្នុងករណីដែលល័ក្ខខ័ណ្ឌនៃការភាន់ច្រឡំត្រូវបានបំពេញ ។

២-ក្នុងករណីដែលភាគីដែលគួរតែអាចដឹងថា អត្ថន័យនៃកិច្ចសន្យាមិនអាចសម្រេចតាំងពីដំបូងបាន នាំឱ្យមានការខូចខាតដល់ភាគីម្ខាងទៀតដោយសារការបង្កើតកិច្ចសន្យា ភាគីនោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដល់ភាគីម្ខាងទៀត ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៣៩៨ (ល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត) នៃក្រមនេះ ។

## ផ្នែកទី ៣
## មោឃភាព និង ការលុបចោល

**មាត្រា ៣៥៦.–** និយមន័យនៃសកម្មភាព

ពាក្យ “សកម្មភាព” ក្នុងផ្នែកទី ៣ (មោឃភាព និង ការលុបចោល) នេះ សំដៅទៅលើកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី ។

**មាត្រា ៣៥៧.-** អត្ថន័យនៃមោឃភាព

ប្រសិនបើអត្ថន័យនៃសកម្មភាព ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន ។ ក្នុងករណីដែលសកម្មភាពត្រូវចាត់ទុកជាមោឃៈ ដោយសារសកម្មភាពនោះផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារឱ្យមាន ដោយក្រមនេះ ឬ ច្បាប់ផ្សេង ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន ។

**មាត្រា ៣៥៨.-** សកម្មភាពដែលអាចលុបចោលបាន

១-សកម្មភាពដែលអាចលុបចោលបាន មានសុពលភាព រហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ ។

២-ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង ។

៣-ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានផ្តល់សច្ចានុមតិលើសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវមានសុពលភាពជាស្ថាពរ ។

**មាត្រា ៣៥៩.-** អ្នកដែលមានសិទ្ធិលុបចោល

១-ចំពោះសកម្មភាពដែលអាចលុបចោលបាន ដោយមូលហេតុថា មានវិការៈក្នុងការបង្ហាញឆន្ទៈដែលបានកំណត់ ចាប់ពីមាត្រា ៣៤៦ (ការភាន់ច្រឡំ) ដល់មាត្រា ៣៥១ (អំពើកេងយកចំណេញហួសហេតុ) នៃក្រមនេះ អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះ អាចលុបចោលនូវសកម្មភាពនោះបាន ។ សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈ ឬ អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ ។

២-ចំពោះការលុបចោល ដោយមូលហេតុគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ អនីតិភាព ឬ ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពផ្សេងទៀត សាមីខ្លួន អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិរញ្ញបត្ថម្ភកៈនៃជននោះ អាចលុបចោលនូវសកម្មភាពបាន ។ សន្តតិជន ឬ អច្ច័យលាភីសកលរបស់សាមីខ្លួន ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ ។

១៣១

**មាត្រា ៣៦០.-** វិធីនៃការលុបចោល ឬ សច្ចានុមតិ

ក្នុងករណីដែលភាគីម្ខាងទៀតនៃសកម្មភាពដែលអាចលុបចោលបាន ត្រូវបានកំណត់ច្បាស់លាស់ ការលុបចោល ឬ សច្ចានុមតិត្រូវធ្វើឡើងដោយការជូនដំណឹងទៅភាគីម្ខាងទៀតនោះ ។ អានុភាពនៃការលុបចោល ឬ សច្ចានុមតិ ត្រូវកើតឡើងនៅពេលដែលដំណឹងនោះបានដល់ភាគីម្ខាងទៀតនោះ ។

**មាត្រា ៣៦១.-** អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ និង លក្ខខណ្ឌនៃការផ្តល់សច្ចានុមតិ

១-អ្នកមានសិទ្ធិលុបចោល អាចផ្តល់សច្ចានុមតិចំពោះសកម្មភាពដែលអាចលុបចោលបាន ។ ប៉ុន្តែ ក្នុងករណីដែលលុបចោលសកម្មភាព ដោយយកការបង្ហាញឆន្ទៈដោយមានវិការៈជាមូលហេតុ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន ចាប់តាំងពីពេលដែលអ្នកមានសិទ្ធិលុបចោលនោះបានដឹងអំពីមូលហេតុនៃការលុបចោល ។ រីឯសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពវិញ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន នៅក្រោយពេលដែលស្ថានភាពដែលជាមូលហេតុនៃការលុបចោលត្រូវរលត់ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ៣ កថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពផ្តល់សច្ចានុមតិ ។

**មាត្រា ៣៦២.-** សច្ចានុមតិដែលច្បាប់បានកំណត់

នៅក្រោយពេលដែលអាចផ្តល់សច្ចានុមតិតាមបញ្ញត្តិនៃមាត្រា ៣៦១ (អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ និង លក្ខខណ្ឌនៃការផ្តល់សច្ចានុមតិ) ខាងលើ សកម្មភាពដែលអាចលុបចោលបាន ត្រូវចាត់ទុកថា បានផ្តល់សច្ចានុមតិរួចហើយ ក្នុងករណីមានហេតុដូចខាងក្រោមនេះ :

ក-ការអនុវត្តកាតព្វកិច្ចទាំងមូល ឬ មួយផ្នែក ចំពោះកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពដែលអាចលុបចោលបាន ឬ ការដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ចនោះ ។

ខ-ការអនុវត្តសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ឬ ការ

១៣២

ទាមទារឱ្យភាគីម្ខាងទៀតអនុវត្ត ។

គ-អនុប្បទាន ឬ ការចាត់ចែងផ្សេងទៀតនូវសិទ្ធិទាំងមូល ឬ មួយផ្នែក ចំពោះសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើមានថបនីយថា ខ្លួនមិនបានផ្តល់សច្ចានុមតិ នៅពេលដែលហេតុដែលបានកំណត់នៅក្នុងករណីទាំងបីខាងលើនោះ កើតឡើង ។

**មាត្រា ៣៦៣.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល

១-ប្រសិនបើអ្នកមានសិទ្ធិលុបចោលមិនអនុវត្តសិទ្ធិនោះក្នុងរយៈពេល ៣ (បី) ឆ្នាំ ចាប់តាំងពីពេលដែលខ្លួនក្លាយទៅជាអ្នកដែលអាចផ្តល់សច្ចានុមតិ នោះសិទ្ធិលុបចោល និង សិទ្ធិទាមទារឱ្យសងសេចក្តីចម្រើនដោយឥតហេតុដែលកើតឡើង ដោយសារការលុបចោលនោះ ត្រូវរលត់ ។ បញ្ញត្តិស្តីពីការផ្អាកអាជ្ញាយុកាលមិនត្រូវយកមកអនុវត្តឡើយ ចំពោះអំឡុងពេលនេះ ។

២-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ប្រសិនបើហួសអំឡុងពេល ១០ (ដប់) ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាព នោះសិទ្ធិលុបចោលក៏ត្រូវរលត់ដែរ ។

៣-ក្នុងករណីដែលបុគ្គលច្រើននាក់មានសិទ្ធិលុបចោលនូវសកម្មភាពតែមួយ បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះត្រូវយកមកអនុវត្ត ចំពោះសិទ្ធិលុបចោលនៃបុគ្គលនីមួយៗនោះ ។

## ផ្នែកទី ៤

## ការតំណាង

**មាត្រា ៣៦៤.–** និយមន័យនៃការតំណាង

ការតំណាងសំដៅទៅលើទំនាក់ទំនងគតិយុត្តដែលអានុភាពនៃកិច្ចសន្យាត្រូវមានចំពោះម្ចាស់សិទ្ធិផ្ទាល់ ក្នុងករណីដែលអ្នកតំណាង ធ្វើកិច្ចសន្យាជាមួយភាគីម្ខាងទៀត

១៣៣